# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




Asian International Justice Initiative (AIJI), a project of East-West Center and UC Berkeley War Crimes Studies Center

> *ទាំងនេះ ជាឯកសារដែលបានកើតឡើងនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ជាឯកសារដែលមិនមែនពាក់ព័ន្ធត្រឹមតែអង្គហេតុប៉ុណ្ណោះទេ ។ វាលើសពីចម្លើយរបស់សាក្សីទៅទៀត ព្រោះហេតុផលផ្សេងៗ គឺត្រូវបានលើកឡើងនៅក្នុងប្រវត្តិរូបនេះ ដោយមានទាំងការពន្យល់ពីអ្នកដទៃទៀត ដែលគាត់មានទំនាក់ទំនងជាមួយ ហើយដែលត្រូវបានគេចោទប្រកាន់ថាជាខ្មាំង ឬក៏ជាជនក្បត់នោះ ។*
>
> \- ***សហព្រះរាជអាជ្ញាអន្តរជាតិលោក ខេល លីសាក់***

## *ជំពូកទី ១៖* ទិដ្ឋភាពទូទៅ

សវនាការនៅសប្តាហ៍នេះ ជាកំណត់ត្រាដ៏សំខាន់នៃកិច្ចចាប់ផ្តើមដំណើរការនីតិវិធីក្នុងដំណាក់កាលទីពីរ វគ្គទី១ នៃសំណុំរឿង០០២ (សំណុំរឿង០០២/០១ ដំណាក់កាលទីពីរ)។ ក្នុងដំណាក់កាលនេះ នីតិវិធីទាំងមូលនឹងផ្តោតសំខាន់ទៅនឹងរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងការងារនៃរបបកម្ពុជាប្រជាធិបតេយ្យ។

ជំនួសឲ្យការចេញសេចក្តីបង្គាប់ដល់ភាគីក្នុងការដាក់សំណើជាលាយលក្ខណ៍អក្សរ អង្គជំនុំជម្រះសាលាដំបូង បានចំណាយពេលវេលាជាច្រើន ដើម្បីស្តាប់នូវការពិភាក្សាដេញដោលពីភាគី ស្តីពីបញ្ហានៃភាពអាចទទួលយកបាននៃឯកសារ។[1] អង្គជំនុំជម្រះ ក៏បានស្តាប់ការជជែកតវ៉ាលើបញ្ហាមួយចំនួនទាក់ទងនឹងសិទ្ធិរបស់ជនជាប់ចោទក្នុងការចូលរួមនីតិវិធីសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ ជាជាងជម្រើសនៃការតាមដានសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍នៅឯបន្ទប់រង់ចាំខាងក្រោម ។

បញ្ហាមួយទៀតដែលតុលាការបានលើកយកមកពិភាក្សានៅសប្តាហ៍នេះផងដែរ គឺភាពសមរម្យក្នុងការស្តាប់សាក្សីជំនាញសំខាន់មួយរូប គឺលោកសាស្ត្រាចារ្យ **ប៊ែន ឃៀរនិន**[2] *(Prof. Ben Kiernan)* តាមប្រព័ន្ធសោតទស្សន៍ជំនួសឲ្យការកោះហៅគាត់ឲ្យចូលខ្លួនមកផ្តល់សក្ខីកម្មដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ។ លោក **ប៊ែន ឃៀរនិន** ជាសាស្ត្រាចារ្យផ្នែកប្រវត្តិសាស្ត្រនៃ**សាកលវិទ្យាល័យយេល** *(Yale University)* មានស្នាដៃនិពន្ធជាច្រើនទាក់ទងនឹងកម្ពុជាប្រជាធិបតេយ្យ និងរបបខ្មែរក្រហម។

ក្រុមមេធាវីការពារក្តី បានបញ្ជាក់ពីការព្រួយបារម្ភលើការសួរដេញដោលទៅលោក **ឃៀរនិន** តាមប្រព័ន្ធសោតទស្សន៍ ដោយសារក្រុមមេធាវីយល់ថា វាអាចមានប្រសិទ្ធភាពតិចតួច និងថា ការសួរដេញដោលសាក្សីជំនាញពីចម្ងាយដូចនេះ គឺមិនអាចឲ្យភាគីវិនិច្ឆ័យពីអត្តចរិតរបស់លោក **ឃៀរនិន** បានទេ ហើយក៏រឹតតែពិបាកយល់បានថាតើសាក្សីជំនាញរូបនេះប្រាប់ពីព័ត៌មានពិត ឬមិនពិតជូនតុលាការ។ ក្រុមការពារក្តីបានស្នើថា ប្រសិនបើអង្គជំនុំជម្រះសម្រេចធ្វើសវនាការស្តាប់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍មែន អង្គជំនុំជម្រះ គួរតែផ្តល់ទម្ងន់តិចតួចប៉ុណ្ណោះចំពោះសក្ខីកម្មបែបនេះ។ សេចក្តីសម្រេចមួយលើបញ្ហានេះ អាចនឹងជះឥទ្ធិពលដល់កិច្ចដំណើរការនីតិវិធីសវនាការជាបន្តបន្ទាប់ទៀត ប្រសិនបើតុលាការមានបំណងស្តាប់សក្ខីកម្មពីសាក្សីនានាតាមមធ្យោបាយសោតទស្សន៍ ជាពិសេស ការគិតគូរពីទម្ងន់ដល់ការធ្វើសក្ខីកម្មរបៀបនេះ ក៏ដូចជាការថ្លឹងថ្លែងអំពីសេចក្តីត្រូវការក្នុងការធានាឲ្យបាននូវប្រសិទ្ធភាពនៃកិច្ចដំណើរការនីតិវិធី និងតម្រូវការឲ្យសាក្សីមួយចំនួនត្រូវបង្ហាញខ្លួននៅក្នុងបន្ទប់តុលាការក្នុងពេលផ្តល់សក្ខីកម្ម។

## *ជំពូកទី ២៖ បញ្ហាច្បាប់ និង នីតិវិធី*

បញ្ហាផ្លូវច្បាប់ និងនីតិវិធី ដែលបានកើតមាននៅសប្តាហ៍នេះ គឺជាបញ្ហាតុល្យភាពជុំវិញសិទ្ធិរបស់ជនជាប់ចោទក្នុងការបង្ហាញខ្លួននៅក្នុងកិច្ចដំណើរការនីតិវិធី សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលការជំនុំជម្រះឲ្យបានឆាប់រហ័ស ក៏ដូចជាសិទ្ធិរបស់ជនជាប់ចោទ ក្នុងការប្រឈមនឹងសាក្សីដែលនឹងត្រូវផ្តល់សក្ខីកម្មប្រឆាំងនឹងពួកគាត់ ព្រមទាំងធនធានដែលអាចប្រើប្រាស់បានក្នុងការសម្របសម្រួលប្រព័ន្ធសោតទស្សន៍ ដើម្បីនឹងស្តាប់នូវសក្ខីកម្មរបស់សាក្សី។ ក្រៅពីបញ្ហាទាំងនេះ ភាគីក៏បានលើកឡើងនូវបញ្ហាមួយចំនួនស្តីពីភាពអាចទទួលយកបាននៃឯកសារ។

### ក. សិទ្ធិរបស់ជនជាប់ចោទក្នុងការបង្ហាញខ្លួនដោយផ្ទាល់នៅក្នុងបន្ទប់តុលាការ

មេធាវីការពារក្តីឲ្យលោក **នួន ជា** បានលើកឡើងនូវបញ្ហាស្តីពីសិទ្ធិមានវត្តមាននៅក្នុងបន្ទប់សវនាការរបស់កូនក្តីពួកគាត់ ជាពិសេសនៅពេលលោក **នួន ជា** ផ្តល់នូវសេចក្តីថ្លែងការណ៍មួយ និងនៅពេលសាក្សី **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច**[3] (តពីនេះនឹងហៅថា លោក **ឌុច**) ចូលខ្លួនមកផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២ នៅសប្តាហ៍ក្រោយ។ មេធាវីអន្តរជាតិការពារក្តី គឺលោក **ម៉ែខល ផេស្តមិន** *(Mr. Michiel PESTMAN)* បានតវ៉ាថា វាជាការ

សំខាន់ណាស់ក្នុងការកែសម្រួលកាលវិភាគសវនាការ ព្រោះបើមិនដូច្នោះទេ កូនក្តីរបស់គាត់នឹងមិនអាចផ្តល់សេចក្តីថ្លែងការណ៍ជូនអង្គជំនុំជម្រះបានឡើយ ហើយក៏មិនអាចបង្ហាញខ្លួនដោយផ្ទាល់ក្នុងបន្ទប់សវនាការបានដែរនាអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់សាក្សី **ឌុច** នៅពេលរសៀលនេះ។ លោក **ផេស្តមិន** បានពន្យល់ប្រាប់តុលាការថា លោក **ឌុច** ជាសាក្សីសំខាន់ណាស់ ហើយអាចនឹងជាសាក្សីតែម្នាក់គត់ដែលអាចផ្តល់នូវភស្តុតាងបញ្ជាក់ពីការជាប់ពាក់ព័ន្ធនឹងបទឧក្រិដ្ឋប្រឆាំងជាមួយកូនក្តីរបស់គាត់[4] ដូចនេះ វាចាំបាច់ណាស់សម្រាប់លោក **នួន ជា** ក្នុងការមានវត្តមានដោយផ្ទាល់ដើម្បីប្រឈមនឹងសាក្សីរូបនេះ (**ឌុច**) ។ លោកមេធាវីបានធ្វើការតវ៉ាទៀតថា ខណៈដែលការផ្លាស់ប្តូរកាលវិភាគនឹងមិនបង្កភាពលំបាកអ្វីជាដុំកំភួនដល់តុលាការ វាជាការសំខាន់សម្រាប់អង្គជំនុំជម្រះ ក្នុងការផ្តល់នូវការគោរពដ៏សមគួរដល់សិទ្ធិរបស់ជនជាប់ចោទ។

លោក **ផេស្តមិន** បានទទួលស្គាល់ចំពោះការខិតខំសម្របសម្រួល ប្រកបដោយការយកចិត្តទុកដាក់លើស្ថានភាពសុខភាពរបស់ជនជាប់ចោទ មានដូចជា៖ ការរៀបចំផ្គត់ផ្គង់ឲ្យមានឧបករណ៍សោតទស្សន៍នៅក្នុងបន្ទប់រង់ចាំខាងក្រោមសាលសវនាការ ដើម្បីឲ្យជនជាប់ចោទអាចតាមដានសវនាការពីចម្ងាយ និងថែមទាំងបានរៀបចំភ្ជាប់នូវប្រព័ន្ធទូរស័ព្ទទាក់ទងជាមួយមេធាវីប្រឹក្សាក្តីរបស់ពួកគាត់ផងដែរ។ ទោះជាយ៉ាងនេះក្តី លោកមេធាវីបានសង្កត់ធ្ងន់ថា វិធានការទាំងនេះ មិនអាចប្រៀបធៀបបានទៅនឹងការដែលជនជាប់ចោទអាចចូលរួមតាមដានដំណើរការនីតិវិធីដោយផ្ទាល់នោះទេ។ បន្ទាប់មកទៀត មេធាវីរូបនេះ បានជំរុញឲ្យអង្គជំនុំជម្រះគោរពនូវឆន្ទៈរបស់លោក **នួន ជា** ដែលបានទាមទារសុំមានវត្តមានតាមដានសវនាការដោយផ្ទាល់ ដោយស្នើឲ្យអង្គជំនុំជម្រះជួយកែសម្រួលកាលវិភាគជាថ្មី ។ មេធាវីអន្តរជាតិការពារក្តីឲ្យលោក **អៀង សារី** គឺលោក **ម៉ៃខល កាណាវ៉ាស** *(Mr. Michael KARNAVAS)* បានគាំទ្រនូវការលើកឡើងរបស់លោក **ផេស្តមិន** និងបានធ្វើការកត់សម្គាល់បន្ថែមថា បញ្ហានេះ អាចនឹងធ្វើឲ្យមានភាពស្មុគស្មាញ ដល់កូនក្តីរបស់គាត់ផងដែរនៅថ្ងៃខាងមុខ។ លោកមេធាវីបានបន្ថែមទៀតថា ប្រសិនបើអង្គជំនុំជម្រះ មិនព្រមទទួលស្គាល់ពីភាពខុសគ្នារវាងការមានវត្តមាននៅក្នុងតុលាការ ដើម្បីតាមដាននីតិវិធីដោយផ្ទាល់ និងការចូលរួមតាមដានតាមរយៈប្រព័ន្ធសោតទស្សន៍ពីបន្ទប់រង់ចាំនោះទេ នោះមិនគួរណាមានការតម្រូវឲ្យជនជាប់ចោទធ្វើលិខិតសុំលះបង់សិទ្ធិមិនចូលរួម នៅពេលពួកគាត់ចាំបាច់ត្រូវស្នើសុំទៅចូលរួមតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់រង់ចាំឡើយ (នៅពេលស្ថានភាពសុខភាពមិនអំណោយផល)។ ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះ មិនគួរណាហាមឃាត់លោក **អៀង សារី** មិនឲ្យទៅកាន់បន្ទប់សោតទស្សន៍ នៅពេលដែលក្រឡាបញ្ជីកំពុងអាននូវបទចោទប្រកាន់ប្រឆាំងលើរូបលោកនោះទេ។ លោក **កាណាវ៉ាស** បានតវ៉ាថា ដោយការហាមឃាត់លោក **អៀង សារី** មិនឲ្យចូលរួមតាមដានកិច្ចដំណើរការនីតិវិធីពីចម្ងាយ អង្គជំនុំជម្រះបានចង្អុលបង្ហាញនូវការទទួលស្គាល់នូវសេចក្តីសម្រេចរបស់ខ្លួនថា អ្វីដែលក្រឡាបញ្ជីនឹងអាន គឺជាផ្នែកសំខាន់ៗនៃកិច្ចដំណើរការនីតិវិធី និងថា ការតម្រូវឲ្យលោក **អៀង សារី** មានវត្តមាន គឺខុសគ្នាមួយរវាងការមានវត្តមានរបស់ជនជាប់ចោទនៅក្នុងបន្ទប់សវនាការ និងការចូលរួមស្តាប់តាមប្រព័ន្ធបណ្តាញសោតទស្សន៍។

ព្រះរាជអាជ្ញាអន្តរជាតិគឺលោក **ឌេល លីសាក់** *(Mr. Dale LYSAK)* បានឆ្លើយតបថា ការផ្លាស់ប្តូរកាលវិភាគដើម្បីតម្រូវទៅនឹងបញ្ហាសុខភាពរបស់លោក **នួន ជា** អាចនឹងជាបន្ទុកហួសហេតុដល់អង្គជំនុំជម្រះ និងជាមធ្យោបាយដែលគ្មានប្រសិទ្ធភាពទាំងនៅក្នុងពេលបច្ចុប្បន្ន នឹងសម្រាប់កិច្ចដំណើរការនីតិវិធីនៅពេលអនាគត។ លោក **លីសាក់** បានថ្លែងថា វេជ្ជបណ្ឌិតជំនាញ គឺលោកសាស្ត្រាចារ្យ **ចន ខាំប៊ែល** *(Mr. John Campbell)* ដែលជាអ្នកបានពិនិត្យសុខភាពរបស់ជនជាប់ចោទដោយផ្ទាល់នោះ បានបញ្ជាក់ប្រាប់តុលាការថា លោក **នួន ជា** មានកាយសម្បទាសមស្របក្នុងការជំនុំជម្រះ ហើយវាប្រាកដណាស់ដែលជនជាប់ចោទរូបនេះ អាចមានសមត្ថភាពអង្គុយតាមដានសវនាការដោយផ្ទាល់បាន ដោយសារគាត់បានទទួលពិន្ទុ ៣០ លើ៣០ លើតេស្តវាស់ស្ទង់សតិបញ្ញា និងថា កម្រិតនេះ អាចប្រៀបធៀបបានជាមួយនឹងអ្នកមានវ័យ២៥ឆ្នាំដូច្នោះដែរ។ ត្រង់ចំណុចនេះ លោក **លីសាក់** បានថ្លែងទៀតថា ការរកឃើញរបស់វេជ្ជបណ្ឌិតជំនាញ ស្តីពីស្ថានភាពកាយសម្បទារបស់លោក **នួន ជា** នឹងនៅតែមានប្រសិទ្ធភាព រហូតទាល់តែមានការបញ្ជាក់ថ្មីផ្សេងទៀតថា លោក **នួន ជា** មិនអាចចូលរួមដោយផ្ទាល់នៅក្នុងតុលាការបានទេ។ សហព្រះរាជអាជ្ញាបានបន្ថែមថា មិនមានភាពចាំបាច់ឡើយក្នុងការពន្យារពេលកិច្ចដំណើរការនីតិវិធីសវនាការដោយគ្រាន់តែមានការអះអាងពីលោក **នួន ជា** ថា គាត់មិនមានកម្លាំង និងហេវហត់ខ្លាំងតែប៉ុណ្ណឹងនោះទេ។ លោក **លីសាក់** បានបន្តធ្វើការជំទាស់ទៀតថា អង្គជំនុំជម្រះ បានផ្តល់នូវការសម្របសម្រួលពេញលេញដោយបានផ្តល់ឱកាសឲ្យជនជាប់ចោទ អាចចូលរួមតាមដានសវនាការបានតាមរយៈប្រព័ន្ធសោតទស្សន៍ នៅពេលស្ថានភាពសុខភាពរបស់ពួកគាត់មិនអំណោយផល ។ ហេតុដូច្នេះ កាលណាគ្មានសេចក្តីបញ្ជាក់ពីវេជ្ជបណ្ឌិតជំនាញថាលោក **នួន ជា** មិនអាចអង្គុយបានពេញមួយថ្ងៃនៅក្នុងបន្ទប់តុលាការនោះទេ មានន័យថា អង្គជំនុំជម្រះ គួរតែធ្វើសវនាការតាមគម្រោងដែលបានគ្រោងទុក បើទោះបីជាលោក **នួន ជា** សម្រេចថាមានវត្តមាន ឬអវត្តមាននៅក្នុងបន្ទប់សវនាការក៏ដោយ ។

អង្គជំនុំជម្រះ មិនបានចេញសេចក្តីសម្រេចដោយចំពោះទៅលើបញ្ហាទាំងនេះឡើយ។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះបានប្រកាសថា សប្តាហ៍ក្រោយ តុលាការនឹងស្តាប់សក្ខីកម្មលោក **នួន ជា** នៅព្រឹកថ្ងៃច័ន្ទ និងព្រឹកថ្ងៃពុធ។ ដោយហេតុនេះ អង្គជំនុំជម្រះនឹងមិនធ្វើសវនាការទេ នៅរសៀលថ្ងៃច័ន្ទ និងថ្ងៃពុធ។ នៅក្នុងសប្តាហ៍ដដែលនេះ តុលាការនឹងស្តាប់សក្ខីកម្មរបស់សាក្សី **ឌុច** ពេញមួយថ្ងៃអង្គារ និងថ្ងៃព្រហស្បតិ៍។ ដោយសារតែអង្គជំនុំជម្រះមិនបានគូសបញ្ជាក់ថាតើ សេចក្តីសម្រេចនេះ កើតចេញពីគោលការណ៍ណាមួយដែលខ្លួនបានយកសម្អាងតាម ឬក៏វាជាការអនុវត្តសម្រាប់តែស្ថានភាពជាក់លាក់បែបនេះ ឬយ៉ាងណា ដូច្នេះធ្វើឲ្យមានភាពមន្ទិលសង្ស័យថា ការអនុវត្តនេះ នឹងបន្សល់ទុកនូវបញ្ហាដែលបានកើតឡើង ក៏ប៉ុន្តែមិនមានដំណោះស្រាយប្រាកដប្រជា ហើយវានឹងនាំឲ្យមានការពិភាក្សាដេញដោលសាជាថ្មីទៀតមិនខាន។[5]

## ខ. ការជំទាស់ចំពោះការធ្វើសក្ខីកម្មរបស់លោកសាស្ត្រាចារ្យ ប៉ែន យៀវនិន តាមប្រព័ន្ធសោតទស្សន៍

នៅខែតុលា ឆ្នាំ២០១១ អង្គជំនុំជម្រះ បានប្រកាសពីគោលបំណងរបស់ខ្លួនថា នឹងស្តាប់សក្ខីកម្មលោកសាស្ត្រាចារ្យ **ប៉ែន យៀវនិន** (TCE-38) ក៏ប៉ុន្តែ ដោយសារតែអង្គជំនុំជម្រះមិនអាចបញ្ជាក់ឲ្យច្បាស់ពីការអាចបង្ហាញខ្លួនបានរបស់សាក្សីជំនាញរូបនេះ (TCE-38) រហូតទាល់តែដល់ខែកុម្ភៈ ឆ្នាំ២០១២ ទើបអង្គជំនុំជម្រះបានសំណូមពរសហព្រះរាជអាជ្ញា (ជាភាគីដែលបានបញ្ចូលលោក **យៀវនិន** នៅក្នុងបញ្ជីឈ្មោះសាក្សី ពោលលោក **យៀវនិន** គឺជាសាក្សីដែលស្នើដោយភាគីសហព្រះរាជអាជ្ញា ដូចនេះ អង្គជំនុំជម្រះត្រូវសួរយោបល់ពីភាគីនេះ) ឲ្យរាយការណ៍ជូនអង្គជំនុំជម្រះ និងភាគីផ្សេងទៀតក្នុងរយៈពេលបីសប្តាហ៍ ថាតើសហព្រះរាជអាជ្ញានឹងផ្តល់អនុសាសន៍ដូចម្តេចខ្លះពាក់ព័ន្ធទៅនឹងការរៀបចំកាលវិភាគ និងរបៀបរបបនៃការស្តាប់សក្ខីកម្មរបស់បុគ្គលនេះថានឹង...ប្រព្រឹត្តទៅតាមរបៀបណាខ្លះ។[6] ភាគីសហព្រះរាជអាជ្ញា បានអនុវត្តតាមការណែនាំ និងបានជូនដំណឹងដល់អង្គជំនុំជម្រះថា លោក **ប៉ែន យៀវនិន** មិនអាចមកកាន់ **អ.វ.ត.ក** បានទេ នៅក្នុងឆ្នាំ២០១២ ប៉ុន្តែប្រហែលជាអាចនៅឆ្នាំ២០១៣។ ហេតុដូចនេះ សហព្រះរាជអាជ្ញា បានស្នើសុំអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក **យៀវនិន** ផ្តល់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍ជំនួសឲ្យការស្តាប់សក្ខីកម្មដោយផ្ទាល់នៅក្នុងបន្ទប់តុលាការ ។ ប្រសិនបើតុលាការអនុញ្ញាតតាមការស្នើនោះ ការធ្វើសក្ខីកម្មរបស់សាក្សីរូបនេះ នឹងអាចធ្វើទៅបានដូចដែលកាលវិភាគបានគ្រោងទុក។ ក្រុមមេធាវីការពារក្តីបានលើកឡើងថា លោក **យៀវនិន** ជាសាក្សីដ៏សំខាន់ ហើយការផ្តល់សក្ខីកម្មរបស់គាត់ត្រូវតែធ្វើឡើងក្នុងបន្ទប់តុលាការ ទោះបីជាសក្ខីកម្មនោះ ត្រូវពន្យារពេលយឺតមួយឆ្នាំក៏ដោយ (ឆ្នាំ២០១៣) ។

លោក **កាណាវាស** បានស្នើថា ការស្តាប់សក្ខីកម្មរបស់សាស្ត្រាចារ្យ **យៀវនិន** ក្នុងគោលបំណងផ្តល់ភស្តុតាងគាំទ្រដល់ការចោទប្រកាន់របស់ខាងការិយាល័យសហព្រះរាជអាជ្ញា អាចធ្វើទៅបានទោះតាមប្រព័ន្ធសោតទស្សន៍នៅពេលបច្ចុប្បន្ន ហើយបន្ទាប់មក តុលាការអាចកោះហៅគាត់ម្តងទៀតនៅឆ្នាំ២០១៣ ឬក៏អាចផ្តល់សក្ខីកម្មទាំងស្រុងនៅឆ្នាំ២០១៣ តែម្តងក៏បាន។ យ៉ាងណាក៏ដោយ ប្រសិនបើអង្គជំនុំជម្រះនៅតែទទូចចង់ស្តាប់សក្ខីកម្មលោកសាស្ត្រាចារ្យ **យៀវនិន** តាមមធ្យោបាយប្រព័ន្ធសោតទស្សន៍ ដូចនេះ អង្គជំនុំជម្រះ គួរតែអនុញ្ញាតឲ្យក្រុមមេធាវីការពារក្តីលោក **នួន ជា** និងលោក **អៀង សារី** ធ្វើដំណើរទៅកាន់សហរដ្ឋអាមេរិក ដើម្បីធ្វើការសួរដេញដោលដោយផ្ទាល់ចំពោះលោក **យៀវនិន** ។ លោក **កាណាវាស** ក៏បានស្នើសុំអង្គជំនុំជម្រះផងដែរ ឲ្យបន្ថយទម្ងន់លើសក្ខីកម្មរបស់លោក **យៀវនិន** ប្រសិនបើចាំបាច់ត្រូវតែស្តាប់សក្ខីកម្មរបស់គាត់តាមរយៈប្រព័ន្ធសោតទស្សន៍។

មេធាវីការពារក្តីបានចង្អុលបង្ហាញថា វាជារឿងធម្មតានៅក្នុងការដែលបុគ្គលណាម្នាក់ត្រូវតែដកឃ្លាជាបណ្តោះអាសន្នពីកាតព្វកិច្ចនានារបស់ខ្លួន និងយកពេលវេលានោះអញ្ជើញមកតាមការកោះហៅរបស់អង្គជំនុំ

ជម្រះ ជាពិសេស នៅពេលដែលអង្គហេតុនៃសក្ខីកម្មនោះ នឹងគ្រប់ដណ្តប់លើលទ្ធផលនៃការស្រាវជ្រាវអស់ជាច្រើនទសវត្សរ៍មកហើយរបស់បុគ្គលជាក់លាក់រូបនេះ (សាស្ត្រាចារ្យ **យៀវនិន**) ។ ក្រុមមេធាវីការពារក្តី ក៏បានធ្វើការជំទាស់ផងដែរថា ការសួរដេញដោលអ្នកជំនាញដ៏សំខាន់រូបនេះ តាមប្រព័ន្ធសោតទស្សន៍ គឺមិនឆ្លើយតបទៅនឹងសិទ្ធិជនជាប់ចោទក្នុងការមានវត្តមាននៅក្នុងបន្ទប់តុលាការ ដើម្បីប្រឈមនឹងសាក្សីដែលនឹងត្រូវផ្តល់សក្ខីកម្មប្រឆាំងរូបគាត់ដូច្នេះឡើយ។[7] បញ្ហានេះ ដោយសារតែសាក្សីនឹងមិនមានប្រតិកម្មដោយរស់រវើក ឬបង្ហាញចំណាប់អារម្មណ៍អំពីទិដ្ឋភាពនៅជុំវិញខ្លួននៅក្នុងសវនាការ (ចំពោះប្រតិកម្មតបរវាងសាក្សី និងភាគីសួរសំណួរពោល គឺវានឹងមានប្រសិទ្ធភាពខុសគ្នារវាងការធ្វើក្នុងបន្ទប់សវនាការ និងមធ្យោបាយសោតទស្សន៍) ហើយរីឯអាកប្បកិរិយារបស់សាក្សីទៀតសោត ក៏មិនអាចត្រូវបានធ្វើការកត់ឲ្យបានស៊ីជម្រៅ ដូចការមានវត្តមានផ្ទាល់ក្នុងតុលាការ។ មិនតែប៉ុណ្ណោះ ភាគីម្ចាស់សំណួរនឹងមិនតទល់ចំពោះមុខសាក្សី ហើយក៏មិនអាចឆ្លើយឆ្លង ឬទំនាក់ទំនងគ្នាដោយភ្នែកនឹងភ្នែកបានដែរ ។ ដើម្បីគាំទ្រនូវការជំទាស់របស់ខ្លួនថា សក្ខីកម្មរបស់លោកសាស្ត្រាចារ្យ **យៀវនិន** មិនគួរត្រូវបានធ្វើឡើងតាមរយៈមធ្យោបាយសោតទស្សន៍ ដោយលោកមេធាវី **កាណាវ៉ាស** បានយោងនូវយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ **អាយ.ស៊ី.ធី.វ៉ាយ**[8] *(ICTY)* និងតុលាការ **អាយ.ស៊ី.ធី.អ័រ**[9] *(ICTR)* ជាសម្អាងបន្ថែម ។

ជាការឆ្លើយតប ភាគីសហព្រះរាជអាជ្ញា បានធ្វើការអះអាងដោយលើកនូវយុត្តាធិការតុលាការព្រហ្មទណ្ឌអន្តរជាតិ **អាយ.ស៊ី.ធី.វ៉ាយ** និង**អាយ.ស៊ី.ធី.អ័រ** ដែលថា សាក្សីអាចនឹងត្រូវបានអនុញ្ញាតឲ្យផ្តល់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍។ សហព្រះរាជអាជ្ញា បានបន្តការតវ៉ារបស់ខ្លួនទៀតថា តុលាការព្រហ្មទណ្ឌអន្តរជាតិ (**អាយ.ស៊ី.ស៊ី**) ក៏អនុញ្ញាតឲ្យធ្វើការផ្តល់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍ដែរ ដូចនេះ **អ.វ.ត.ក** គួរណាតែធ្វើការពិនិត្យពិច័យ និងអនុវត្តតាមតុលាការព្រហ្មទណ្ឌអន្តរជាតិ (**អាយ. ស៊ី.ស៊ី**) ជាតុលាការអន្តរជាតិមួយ ដែលមានប្រព័ន្ធដូចគ្នាច្រើនជាមួយ **អ.វ.ត.ក** បើប្រៀបធៀបជាមួយតុលាការ **អាយ.ស៊ី.ធី.វ៉ាយ** និងតុលាការ **អាយ.ស៊ី.ធី.អ័រ** ។ លោកសហព្រះរាជអាជ្ញាជាតិ **ច័ន្ទ តារាស្មី** បានសម្អាងថាបើយោងតាមវិធាន ២៦.១ ហើយនិងការអនុវត្តន៍កន្លងទៅរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ គឺថាអង្គជំនុំជម្រះគួរអនុញ្ញាតឲ្យប្រើប្រាស់ប្រព័ន្ធសោតទស្សន៍នៅក្នុងការស្តាប់សក្ខីកម្ម។ សហព្រះរាជអាជ្ញាបានបន្ថែមទៀតថា ការប្រើប្រាស់ប្រព័ន្ធសោតទស្សន៍ គឺមធ្យោបាយសមស្របមួយឆ្លើយតបនឹងវិធានផ្ទៃក្នុង ២៦.១ ពីព្រោះវាអនុញ្ញាតឲ្យទាំងអង្គជំនុំជម្រះ និងភាគីអាចធ្វើការសួរដេញដោលសាក្សីបាននៅពេលវេលាដ៏ត្រឹមត្រូវ ។ សហព្រះរាជអាជ្ញាក៏បានចង្អុលបង្ហាញថា ក្នុងសំណុំរឿង០០១ និង សំណុំរឿង០០២ អង្គជំនុំជម្រះ ធ្លាប់បានស្តាប់សក្ខីកម្មពីបុគ្គលមួយចំនួនរួចមកហើយ តាមរយៈប្រព័ន្ធសោតទស្សន៍ទាំងនៅក្នុងប្រទេសកម្ពុជា និងនៅក្រៅប្រទេស។[10]

ក្នុងការដាក់សំណើរបស់ខ្លួន ភាគីសហព្រះរាជអាជ្ញា បានយោងនូវការអះអាងយ៉ាងទូលំទូលាយនៃវិធាន ២៦.១ ដែលផ្តល់ឲ្យអង្គជំនុំជម្រះនូវឆន្ទានុសិទ្ធិយ៉ាងពេញលេញ ក្នុងការស្តាប់សក្ខីកម្មសាក្សីតាមប្រព័ន្ធសោតទស្សន៍ដោយបានបញ្ជាក់ថា៖

*សក្ខីកម្មរបស់សាក្សី ឬអ្នកជំនាញនៅក្នុងអំឡុងពេលស៊ើបសួរ ឬការជំនុំជម្រះ ត្រូវធ្វើឡើងដោយមានវត្តមានរបស់បុគ្គលនោះផ្ទាល់ នៅពេលណាដែលអាចធ្វើទៅបាន។ ក៏ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ អាចអនុញ្ញាតឲ្យសាក្សីធ្វើសក្ខីកម្មតាមរយៈបច្ចេកវិទ្យាសោតទស្សន៍ ឬទូរទស្សន៍ក្នុងករណីដែលបច្ចេកវិទ្យាបែបនេះអនុញ្ញាតឲ្យសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ និងភាគីសាកសួរសាក្សីបាន នៅពេលដែលសាក្សីត្រូវឡើងធ្វើសក្ខីកម្ម។ បច្ចេកវិទ្យានេះមិនត្រូវអនុញ្ញាតឲ្យប្រើទេ ប្រសិនបើធ្វើឲ្យមានអន្តរាយធ្ងន់ធ្ងរ ឬមិនស្រមទៅនឹងសិទ្ធិការពារខ្លួន។*

លោក **កាណាវ៉ាស** បានលើកឡើងថា៖ លោកសាស្ត្រាចារ្យ **ឃៀរនិន** ជាក់ស្តែងជាសាក្សីជំនាញសម្រាប់គាំទ្រភាគីសហព្រះរាជអាជ្ញា ហេតុដូច្នេះ សហព្រះរាជអាជ្ញាក៏មិនបញ្ចេញឲ្យអស់នូវបន្ទុកនៃការបង្ហាញភស្តុតាង ដើម្បីបង្ហាញពីសេចក្តីត្រូវការផ្នែកនីត្យានុកូលភាព (ភាពត្រឹមត្រូវតាមច្បាប់) ចំពោះការផ្តល់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍របស់សាក្សីរូបនេះដែរ។ សហព្រះរាជាអាជ្ញាបានឆ្លើយតបថា តាមពិតទៅ គឺអង្គជំនុំជម្រះជាអ្នកដែលបានទាមទារឲ្យសហព្រះរាជាអាជ្ញាធ្វើការទំនាក់ទំនងទៅលោក **ឃៀរនិន** ជាសាក្សីជំនាញក្នុងសំណុំរឿងនេះ និងថា បើយោងតាមខ្លឹមសារដែលបានចែងនៅក្នុងវិធានផ្ទៃក្នុង ២៦.១ មិនបានដាក់បញ្ញត្តិឲ្យសហព្រះរាជអាជ្ញាជាអ្នកមានបន្ទុកបង្ហាញភស្តុតាងនោះទេ។

ក្រៅពីបញ្ហាដែលបានលើកឡើងជាហូរហែទាំងនេះ មានហេតុការណ៍មួយទៀតក៏បានកើតឡើងផងដែរទាក់ទងទៅនឹងការបែកធ្លាយនូវឯកសារមួយចំនួន។ លោក **កាណាវ៉ាស** បានស្នើសុំនូវលទ្ធភាពទទួលបានពីការឆ្លើយឆ្លង ឬការទំនាក់ទំនងគ្នារវាងលោក **ឃៀរនិន** និងភាគីសហព្រះរាជអាជ្ញា ដើម្បីធ្វើការបញ្ជាក់បង្ហាញនូវការទាមទាររបស់សាស្ត្រាចារ្យ **ឃៀរនិន** ថានឹងអាចមក **អ.វ.ត.ក** នៅឆ្នាំក្រោយ គឺជាការពិត (ចង់ដឹងពីអង្គហេតុនៃការធ្វើទំនាក់ទំនងរវាងសហព្រះរាជអាជ្ញា និងលោក **ឃៀរនិន**) ។ ជាលទ្ធផលនៃការទាមទារនេះ សហព្រះរាជអាជ្ញា បានផ្តល់ឯកសារមួយច្បាប់ស្តីពីការឆ្លើយឆ្លងគ្នា ដែលការិយាល័យសហព្រះរាជអាជ្ញាបានធ្វើកន្លងមកជាមួយនឹងលោក **ឃៀរនិ**ន ទៅឲ្យក្រុមមេធាវីការពារក្តីនៅអំឡុងពេលសម្រាកសវនាការ ។ ក្នុងបំណងរៀបចំត្រៀមការសួរដេញដោលទៅកាន់លោក **ឃៀរនិន** មេធាវីការពារក្តីឲ្យលោក **អៀង សារី** បានដាក់សំណើជាលាយលក្ខណ៍អក្សរដើម្បីស្នើសុំកំណត់ត្រាដែលសរសេរដោយដៃ និងខ្សែអាត់ថ៍ជាសំឡេងនានា ដែលលោកសាស្ត្រាចារ្យបានប្រើប្រាស់ សម្រួលដល់ការសរសេរសៀវភៅ និងអត្ថបទផ្សេងៗរបស់គាត់។ ក្រៅអំពីការឆ្លើយតបជាលាយលក្ខណ៍អក្សរប្រឆាំងទៅនឹងការស្នើសុំរបស់ភាគីការពារក្តី សហព្រះរាជអាជ្ញាក៏បានធ្វើការជំទាស់ដោយផ្ទាល់មាត់ផងដែរ ដោយបានចាត់ទុកថា វាជាការស្នើសុំហួសហេតុពេក ជាការស្នើដែលមានលក្ខណៈស្រពិចស្រពិល និងខ្វះការយកចិត្តទុកដាក់ ហើយថែមទាំងបានចង្អុលបង្ហាញថា តុលាការមិនអាចបង្ខំលោក **ឃៀរនិន** ឲ្យផ្តល់នូវកំណត់សម្គាល់ផ្ទាល់ខ្លួនរបស់គាត់បានទេ។ ភ្លាមៗនោះលោក **កាណាវ៉ាស** បានឆ្លើយតបថាក្រុមលោក

មិនបានស្នើសុំឲ្យអង្គជំនុំជម្រះ ធ្វើការចងក្រងរាល់កំណត់សម្គាល់ទាំងអស់ដែលលោក **យឿរនិន** មាននោះទេ ក៏ប៉ុន្តែវាអាចនឹងមានឱកាសណាមួយដែលអាចធ្វើទៅបាន ឬបើសហព្រះរាជអាជ្ញាមានឆន្ទៈនោះ "វាគ្មានអ្វីដែលខាតបង់ វាគ្មានអ្វីដែលគួរឲ្យប៉ះពាល់អីទេ" ដោយគ្រាន់តែធ្វើការស្នើសុំប៉ុណ្ណឹង។[11]

## គ. សិទ្ធិផ្សេងៗទៀតរបស់ជនជាប់ចោទ

មានបញ្ហាពីរដែលទាក់ទងនឹងសិទ្ធិរបស់ជនជាប់ចោទត្រូវបានលើកឡើង។ បញ្ហាទី១ គឺអង្គជំនុំជម្រះបានទាមទារឲ្យលោក **អៀង សារី** ត្រូវតែមានវត្តមាននៅក្នុងបន្ទប់សវនាការ ដើម្បីស្តាប់ការចោទប្រកាន់ចែងក្នុងដីកាដំណោះស្រាយប្រឆាំងលើរូបលោកផ្ទាល់ មុនពេលដែលជនជាប់ចោទរូបនេះ ត្រូវបានអនុញ្ញាតឲ្យត្រឡប់ទៅកាន់បន្ទប់រង់ចាំវិញ (បន្ទប់សោតទស្សន៍នៅក្រោមសាលសវនាការ)។ បញ្ហាទី២ អង្គជំនុំជម្រះ បានបដិសេធចំពោះការស្នើសុំពីមេធាវីការពារក្តី លោក **នួន ជា** ក្នុងការធ្វើសំណើជាលាយលក្ខណ៍អក្សរជំទាស់ទៅលើឯកសារនានាមួយចំនួន ។

### *គ.១. អង្គជំនុំជម្រះបានបដិសេធលើសំណើលោក អៀង សារី ក្នុងការតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់រង់ចាំនៅក្រោមសាលសវនាការ*

កាលពីថ្ងៃច័ន្ទមុនសម្រាកពេលព្រឹកបន្តិច មេធាវីជាតិការពារក្តីឲ្យលោក **អៀង សារី** គឺលោក **អាង ឧត្តម** បានជូនដំណឹងពីការស្នើសុំរបស់កូនក្តីគាត់ ដែលទាមទារឲ្យមានការអនុគ្រោះពីតុលាការ ចំពោះការមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ ក៏ប៉ុន្តែបានស្នើសុំចូលរួមតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់សោតទស្សន៍វិញ។ ចាប់តាំងពីខែមករារហូតដល់បច្ចុប្បន្ននេះ លោក **អៀង សារី** បានធ្វើសំណើសុំលះបង់សិទ្ធិចូលរួមនេះជារៀងរាល់ថ្ងៃ បន្ទាប់ពីការសម្រាកសវនាការពេលព្រឹក ពោលគឺជនជាប់ចោទអាចចូលរួមតាមដានបានត្រឹមតែវគ្គទី១ ក្នុងចំណោម៤វគ្គក្នុងមួយថ្ងៃ។ នីតិវិធីនៃការស្នើនេះ គឺថាជនជាប់ចោទត្រូវចុះហត្ថលេខា ឬផ្តិតមេដៃ ដោយមានបញ្ជាក់ពីការបោះបង់សិទ្ធិមានវត្តមានក្នុងបន្ទប់តុលាការ។ ដោយឡែក គ្រានេះ អង្គជំនុំជម្រះ បានបដិសេធលើការស្នើសុំរបស់លោក **អៀង សារី** មិនឲ្យគាត់មានវត្តមាននៅបន្ទប់សោតទស្សន៍ទេដោយលើកហេតុថា វាមានសារៈសំខាន់ណាស់សម្រាប់ការវត្តមានរបស់ជនជាប់ចោទនៅក្នុងបន្ទប់តុលាការដើម្បីស្តាប់នូវការចោទប្រកាន់ប្រឆាំងលើរូបគាត់។ ដោយហេតុនេះ លោក **អៀង សារី** ត្រូវនៅអង្គុយស្តាប់ រហូតក្រឡាបញ្ជីអានបញ្ចប់នូវផ្នែកដែលពាក់ព័ន្ធនៃដីកាដំណោះស្រាយ ក្នុងសវនាការវគ្គពិភាក្សាទីពីរពេញមួយព្រឹក (២វគ្គ) ទើបអ្នកយាមអាចនាំខ្លួនគាត់ទៅកាន់បន្ទប់សោតទស្សន៍វិញបាន តាមការបញ្ជាពីប្រធានតុលាការ ។

### *គ.២. លោក នួន ជា អាចនឹងមិនដាក់សំណើជាលាយលក្ខណ៍អក្សរជំទាស់ទៅនឹងឯកសារនានាទេ*

នៅថ្ងៃច័ន្ទ មេធាវីអន្តរជាតិការពារក្ដីឲ្យលោក **នួន ជា** គឺលោក **អេនឌ្រូ អ៊ីនូហ្ស៊ី** *(Andrew IANUZZI)* បានជូនដំណឹងទៅអង្គជំនុំជម្រះថា ពួកគេនឹងធ្វើបទបង្ហាញនូវការជំទាស់ទូទៅ លើឯកសារនៅក្នុងបន្ទប់សវនាការសាធារណៈក្នុងថ្ងៃនេះ ហើយពួកគាត់នឹងធ្វើការដាក់សំណើជាលាយលក្ខណ៍អក្សរលើការជំទាស់ជាក់លាក់នៅថ្ងៃស្អែក។ ខណៈពេលអង្គជំនុំជម្រះ បានអនុញ្ញាតឲ្យមេធាវីការពារក្ដីលោក **នួន ជា** ធ្វើការជំទាស់ដោយផ្ទាល់មាត់ អង្គជំនុំជម្រះបានសម្រេចថា នឹងមិនទទួលយកនូវការជំទាស់ជាក់លាក់ណាផ្សេងទៀតពីក្រុមនេះទេ ដោយសារតែមេធាវីមិនបានប្រើប្រាស់ពេលវេលាដែលអង្គជំនុំជម្រះបានកំណត់ឲ្យ (ពេញមួយរសៀលថ្ងៃច័ន្ទ) សម្រាប់លើកឡើងនូវការជំទាស់របស់ពួកគេ។ មានន័យថា ក្រុមនេះ ទទួលបានរយៈពេលកន្លះថ្ងៃដើម្បីធ្វើការជំទាស់ទោះត្រូវធ្វើតាមរូបភាពណាក៏ដោយ ។

វាអាស្រ័យទាំងស្រុងទៅលើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះ ថាតើអនុញ្ញាត ឬមិនអនុញ្ញាតឲ្យដាក់សំណើជាលាយលក្ខណ៍អក្សរ ដើម្បីបញ្ជាក់អះអាងនូវការជំទាស់ផ្ទាល់មាត់។ លើសពីនេះ គឺថាតាមកាលវិភាគតុលាការដែលបានជូនដំណឹងដល់ភាគី និងសាធារណជនបានឲ្យដឹងថា សវនាការលើឯកសារសប្ដាហ៍នេះគឺមានបំណងស្ដាប់នូវការដាក់សំណើនានាជាលាយលក្ខណ៍អក្សរ។[12] ទោះបីជាយ៉ាងណាក្ដី វាប្រហែលជាអាចធ្វើឲ្យមានការខូចប្រយោជន៍ដល់ក្រុមការពារក្ដីរបស់លោក **នួន ជា** ទាក់ទងការមានលទ្ធភាពពេញលេញសម្រាប់រៀបចំការពារកូនក្ដីរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព[13] ប្រសិនបើពួកគាត់ត្រូវបានតុលាការជូនដំណឹងពីកាលវិភាគនេះ ក្នុងពេលវេលាមួយដែលធ្វើឲ្យពួកគេគ្មានជម្រើសក្រៅពីការបកស្រាយផ្ទាល់មាត់ ហើយបើការបកស្រាយផ្ទាល់មាត់របស់ពួកគេនាឱកាសនេះ ធ្វើឡើងក្នុងបំណងគាំទ្រដល់សំណើជាលាយលក្ខណ៍អក្សរ តែមិនត្រូវបានអនុញ្ញាត។

## ឃ. ការទទួលយកប្រភេទផ្សេងៗនៃឯកសារ

នៅសប្ដាហ៍នេះ អង្គជំនុំជម្រះបានស្ដាប់លើការជំទាស់ និងសេចក្ដីសម្អាងនានាពីភាគីចំពោះការទទួលយកភស្តុតាងជាឯកសារ។ ដោយសារតែពុំមានការជំទាស់លើឯកសាររបស់ក្រុមមេធាវីការពារក្ដី ឲ្យជនជាប់ចោទពីសំណាក់ភាគីសហព្រះរាជអាជ្ញា និងភាគីមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ទើបធ្វើឲ្យកិច្ចដំណើរការនីតិវិធីត្រូវបានផ្ដោតសំខាន់តែទៅលើឯកសារទាំងឡាយដែលភាគីសហព្រះរាជអាជ្ញា និងភាគីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានបំណងនឹងយកមកប្រើប្រាស់។ ខណៈដែលការពិភាក្សាជាច្រើនមានភាពប្រហាក់ប្រហែលគ្នានឹងប្រធានបទដែលត្រូវបានពិភាក្សាកាលពីសវនាការស្ដីពីភស្តុតាងនាពេលមុនៗ ក្នុងសប្ដាហ៍នេះ ឃើញមានបញ្ហាបីត្រូវបានគ្រប់ដណ្ដប់នៅក្នុងការជជែកដេញដោលលើកទី១៖ (ក) ភាពពាក់ព័ន្ធនៃឯកសារ (ខ) ភស្តុតាងនានាដែលបានពីការធ្វើទារុណកម្ម (គ) ការទទួលយកប្រតិចារឹកនៃសំណុំរឿង០០១ ជាឯកសារភស្តុតាង ។

### *ឃ.១. តើឯកសារណាខ្លះ ដែលពាក់ព័ន្ធទៅនឹងសវនាការដំណាក់កាលដំបូងនៃសំណុំរឿងករណី០០២/០១?*

ក្រុមមេធាវីការពារក្តីបានជំទាស់ថា ឯកសារមួយចំនួនដែលតុលាការនឹងទទួលយកដើម្បីប្រើប្រាស់ក្នុងការកាត់សេចក្តី គួរតែមានការពាក់ព័ន្ធខ្លាំងទៅលើសំណុំរឿង ០០២/១ (ឧទាហរណ៍ ឯកសារស្តីពីប្រវត្តិកម្ពុជាប្រជាធិបតេយ្យ រចនាសម្ព័ន្ធរដ្ឋបាលនៃរបបកម្ពុជាប្រជាធិបតេយ្យ និងតួនាទីរបស់ជនជាប់ចោទ)។ ពួកគាត់បានចង្អុលបង្ហាញថា សហព្រះរាជអាជ្ញា មិនត្រឹមតែមិនបានកែសម្រួលបញ្ជីឯកសារដែលគ្រប់ដណ្តប់តែលើបញ្ហានានាពាក់ព័ន្ធទៅនឹងសវនាការនៃសំណុំរឿង០០២ ដំណាក់កាលទី១ ប៉ុណ្ណោះទេ សហព្រះរាជអាជ្ញា ក៏បានយល់ខុសពីគោលបំណងនៃដីកាបំបែកសំណុំរឿងផងដែរ។[14] ហេតុដូចនេះហើយ បានជាក្រុមមេធាវីការពារក្តីបាននាំគ្នាធ្វើការជំទាស់លើឯកសារម្តងមួយៗ បូករួមទាំងប្រភេទនៃឯកសារនានា ដែលពួកគាត់គិតថាមិនមានការជាប់ពាក់ព័ន្ធនឹងសំណុំរឿង និងថែមទាំងបានស្នើសុំឲ្យអង្គជំនុំជម្រះ ដកនូវឯកសារទាំងនោះចេញពីសវនាការនៃដំណាក់កាលទី១ នេះ។

លោក **អ៊ីនូហ្ស៊ី** បានតវ៉ាថា មានឯកសារជាច្រើន ចាប់ពីឧបសម្ព័ន្ធលេខរៀងទី៦ ដល់ទី២០ ឯកសារក្នុងឧបសម្ព័ន្ធលេខរៀងទី៧ លេខ៨ លេខ៩ និងលេខ១៤ ក៏ដូចជាឯកសារដទៃទៀតដែលមាននៅក្នុងឧបសម្ព័ន្ធលេខ១៣ លេខ១៥ លេខ១៧ លេខ១៨ និងលេខ១៩ គឺមិនមានភាពពាក់ព័ន្ធ ឬមិនស្ថិតនៅក្នុងវិសាលភាពនៃសវនាការដំណាក់កាលដំបូងទេ។ លោក **កាណាវ៉ាស** បានគាំទ្រទៅនឹងការជំទាស់ទាំងនេះ និងក៏បានទាញយកឯកសារជាក់លាក់មួយចំនួន ដែលគាត់ចាត់ទុកថាជាឯកសារដែលមិនមានការជាប់ពាក់ព័ន្ធ រួមមានដូចជា៖ ផែនទី រូបភាព និងសៀវភៅស្តីពីជនជាតិភាគតិចកម្ពុជា-វៀតណាម ព្រមទាំងការសម្ភាសន៍របស់លោកស្រី **អៀង ធីរិទ្ធ** ជាជនជាប់ចោទម្នាក់ដែលអង្គជំនុំជម្រះបានបំបែកគាត់ចេញពីក្នុងសំណុំរឿង០០២ រួចហើយ។ មេធាវីជាតិការពារក្តីឲ្យលោក **ខៀវ សំផន** គឺលោក **គង់ សំអុន** បានយល់ស្របជាមួយលោក **កាណាវ៉ាស** ចំពោះការទាញយកការអះអាងលើករណីលោកស្រី **អៀង ធីរិទ្ធ** និងបានបន្ថែមទៀតថា ឯកសារដែលទាក់ទងនឹងការចោទប្រកាន់ ស្តីពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ គឺមិនពាក់ព័ន្ធទៅនឹងសវនាការវគ្គនេះទេ ហើយក៏មិនត្រូវយកអង្គហេតុនានាចេញពីឯកសារទាំងនេះមកធ្វើការសួរដេញដោលនោះឡើយ។ សហភាគាអន្តរជាតិលោក **គង់ សំអុន** គឺលោកស្រី **អង់តា ហ្គីសេ** *(Ms. Anta Guissé)* បានជំទាស់ទៅនឹងឯកសារនៃឧបសម្ព័ន្ធលេខ៦ លេខ៨ លេខ១៤ និងលេខ១៥ ដែលជាឯកសាររបស់ភាគីសហព្រះរាជអាជ្ញា ព្រមទាំងបានជំទាស់នឹងឯកសារចំនួន៩ ក្នុងចំណោមឯកសារចំនួន១០ផ្សេងទៀត ពីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយអះអាងថា ឯកសារទាំងនេះមិនស្ថិតនៅក្នុងដែនវិសាលភាពនៃសវនាការវគ្គនេះ ។

សហព្រះរាជអាជ្ញាបានតវ៉ាថា ដោយសារតែបញ្ហានៃការទទួលយកឯកសារនៅតែជាចំណោទសំណួរនៅឡើយ (ភាគីដាក់បង្ហាញឯកសារ ហើយអង្គជំនុំជម្រះនឹងធ្វើការសម្រេចពីការទទួលស្គាល់) ក្រោមហេតុផលថា

អ្វីដែលភាគីនានាគួរធ្វើ គឺត្រូវផ្តល់នូវបរិបទលើបទឧក្រិដ្ឋកម្មនានា ដែលមានសារៈសំខាន់សម្រាប់អង្គជំនុំជម្រះអាចធ្វើការសម្រេចនូវការវិនិច្ឆ័យជាផ្លូវការមួយបាន។ ហេតុដូច្នោះ វាមិនសមរម្យទេក្នុងការកម្រិតលើភាពអាចទទួលយកបាននូវឯកសារ ដែលគ្រាន់តែចាត់ទុកថា មានភាពជាប់ពាក់ព័ន្ធខ្ពស់ទៅនឹងបញ្ហាជាក់លាក់សម្រាប់សវនាការដំណាក់កាលនេះ។ ដើម្បីគាំទ្រចំពោះការលើកឡើងទាំងនេះ ជំនួយការជាតិជាន់ខ្ពស់នៃខាងការិយាល័យសហព្រះរាជអាជ្ញា គឺលោក **វ៉េង ហ៊ាត់** បានទាយកខ្លឹមសារចែងក្នុងវិធាន ៨៧.៣[15] នៃ **អ.វ.ត.ក** ដែលបានរៀបរាប់ពីហេតុផលសម្រាប់អង្គជំនុំជម្រះអាចនឹងធ្វើការបដិសេធភស្តុតាងចោលបាន។ បន្ទាប់មក សហព្រះរាជអាជ្ញាអន្តរជាតិ លោក **ថារីក អាប់ឌុលឡាក់** *(Mr. Tarik ABDULHAK)* បានឆ្លើយតបទៅនឹងការជំទាស់របស់ក្រុមមេធាវីការពារក្តីចំពោះឯកសារជាក់លាក់មួយចំនួន ដោយបានធ្វើបទបង្ហាញ ថាតើចំណុចណាខ្លះដែលថាឯកសារទាំងឡាយពីភាគីសហព្រះរាជអាជ្ញា គឺអាចជឿជាក់បាន និងមានការជាប់ពាក់ព័ន្ធ។ លោកបានបន្តការតវ៉ាទៀតថា ចរិតលក្ខណៈនៃដីកាបំបែកកិច្ចដំណើរការនីតិវិធី មិនមានលក្ខខណ្ឌតម្រូវឲ្យធ្វើការកាត់បន្ថយនូវវិសាលភាពនៃសំណុំរឿងក្តីនេះទេ ប៉ុន្តែវាគ្រាន់តែជាការរៀបចំឲ្យបទចោទប្រកាន់ទាំងឡាយនៅតាមលំដាប់លំដោយ និងធ្វើឲ្យការគ្រប់គ្រងសំណុំរឿងទាំងមូលកាន់តែបានល្អប្រសើរ។ លោក **ថារីកអាប់ឌុលឡាក់** បានធ្វើការបញ្ជាក់ថា ដើម្បីបង្ហាញពីការពាក់ព័ន្ធផ្សេងៗឆ្លើយតបនឹងការចោទប្រកាន់នូវបទល្មើសក្នុងសហឧក្រិដ្ឋកម្មរួម ការិយាល័យសហព្រះរាជអាជ្ញា ត្រូវតែបង្ហាញពីចំណងទាក់ទងគ្នារវាងតួនាទីនានានៃផ្នែករដ្ឋបាល ផ្នែកទំនាក់ទំនងគ្នារវាងជនជាប់ចោទ ព្រមទាំងបង្ហាញឲ្យឃើញនូវការវាយប្រហារជាលក្ខណៈប្រព័ន្ធទៅលើក្រុមមួយជាក់លាក់។

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើការគាំទ្រនូវការអះអាងរបស់សហព្រះរាជអាជ្ញា ដោយបានថ្លែងថា ការផ្តល់នូវបរិបទនៃភស្តុតាង គឺមានសារៈសំខាន់ ហើយគួរតែត្រូវបានតុលាការទទួលយក។ លោកស្រី **អេលី ហ្សាបេត ស៊ីម៉ុនណូហ្វត** *(Ms. Elisabeth SIMONNEAU-FORT)* បានថ្លែងថា ឯកសារទាំង ១០ ពីភាគីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សវនាការដំណាក់កាលដំបូងនេះ គឺមានការជាប់ពាក់ព័ន្ធជាក់លាក់ទៅនឹងការជម្លៀសដោយបង្ខំ ក៏ដូចជាបរិបទនៃការប្រព្រឹត្តឧក្រិដ្ឋកម្ម។

### *ឃ.២. ភស្តុតាងដែលបានទទួលពីការធ្វើទារុណកម្ម*

ក្រុមមេធាវីការពារក្តី បានធ្វើការបដិសេធទៅលើឯកសារទាំងអស់ដែលទទួលបានតាមរយៈទារុណកម្ម ឬក្នុងល័ក្ខខ័ណ្ឌបង្ខិតបង្ខំ។ លោក **សុន អរុណ** បានបញ្ជាក់ថា "**ឌុច** បាននិយាយហើយថា ចម្លើយសារភាព យក--បានមកដោយបង្ខំ"[16] ហើយឯកសារទាំងនោះ មិនអាចប្រើប្រាស់សម្រាប់ពិនិត្យរកការពិតបានទេ។ រីឯសហភាតាអន្តរជាតិរបស់គាត់ គឺលោក **អ៊ីនូហ្ស៊ី** បានបន្ថែមទៀតថា រាល់ឯកសារទាំងអស់នៅក្នុងឧបសម្ព័ន្ធលេខរៀងទី៦ គឺសុទ្ធតែបានមកពីការធ្វើទារុណកម្ម និងដោយការបង្ខិតបង្ខំ។ លោកមេធាវី ក៏បានដកស្រង់នូវការរម្លឹកផ្ទាល់មាត់មួយរបស់ប្រធានអង្គជំនុំជម្រះ ថៅក្រម **និល ណុន** ដែលបានធ្វើក្នុងពេលដំណើរការនីតិវិធីនៃសំណុំរឿង០០១ កាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៩ យ៉ាងដូច្នេះថា៖ អង្គជំនុំជម្រះសូមធ្វើការរម្លឹកដល់ភាគីអំពីខ្លឹមសារនៃមាត្រា

១៥ ស្តីពីអនុសញ្ញាប្រឆាំងទារុណកម្ម ដែលត្រូវតែអនុវត្តនៅក្នុងតុលាការនេះផងដែរ ។[17] មេធាវីរូបនេះ ក៏ដកស្រង់នូវសេចក្តីថ្លែងការណ៍របស់លោកស្រីចៅក្រម **ស៊ីលវៀ ខាតរ៉ាយថ៍** *(Judge Sylvia Cartwright)* កាលពីថ្ងៃទី២៨ ខែ ឆ្នាំ២០០៩ ដូចតទៅ ៖

> *អង្គជំនុំជម្រះ សូមបញ្ជាក់អំពីសារៈសំខាន់នៃអង្គហេតុដែលត្រូវគោរពតាមអនុសញ្ញាប្រឆាំងនឹងការទារុណកម្ម ដូចមានចែងក្នុងមាត្រា១៥...ខនេះ ក៏មានឆ្លុះបញ្ចាំងនៅក្នុងមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា និងក្នុងវិធាន២១(៣) នៃអ.វ.ត.ក ។... ចំណុចនេះមានន័យថា ការបង្ហាញនូវការពិតមួយថា ពិតជាមានការសួរនាំឲ្យបានចម្លើយសារភាពមួយ ហើយដែលចម្លើយសារភាពនោះ ត្រូវបានធ្វើឡើងដោយការធ្វើទារុណកម្ម នោះវាជាអង្គហេតុដែលអាចទទួលយកបាន ។ ទោះជាយ៉ាងនេះក្តី ខ្លឹមសារនានានៃចម្លើយសារភាពនោះ នឹងមិនអាចទទួលយកជាសេចក្តីថ្លែងការណ៍ដ៏គួរឲ្យទុកចិត្តបាននោះទេ។[18]*

ស្រដៀងគ្នានេះដែរ លោក **កាណាវាស** បានតវ៉ាថា ឯកសារដែលបានមកតាមរយៈការធ្វើទារុណកម្មនឹងមិនអាចត្រូវបានទទួលយកឡើយ។ លោកស្រី **ហ្គីសសេ** ក៏បានជំទាស់ទៅនឹងឯកសារក្នុងឧបសម្ព័ន្ធលេខរៀងទី ៩ និងឧបសម្ព័ន្ធទី១០ ដោយបានលើកនូវហេតុផលសម្អាងដូចគ្នា។ មុននឹងធ្វើការឆ្លើយតបទៅកាន់ក្រុមមេធាវីការពារក្តី ភាគីសហព្រះរាជអាជ្ញា បានអានសម្រង់ចេញពីមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ការប្រព្រឹត្តអំពើព្រៃផ្សៃ អំពើអមនុស្សធម៌ ឬអំពើដែលនាំឲ្យបាត់បង់តម្លៃជាមនុស្ស បូករួមទាំងការប្រព្រឹត្តនូវទារុណកម្មផ្សេងៗទៀត (កម្ពុជាក៏ជារដ្ឋហត្ថលេខីមួយផងដែរ)៖

> *រដ្ឋភាគី ត្រូវធានាថា ឯកសាររាយការណ៍ទាំងឡាយ (សេចក្តីថ្លែងការណ៍) ដែលបង្កើតឡើងបានមកពីអំពើទារុណកម្ម មិនត្រូវយកមកសំអាងជាធាតុនៃភស្តុតាងនៅក្នុងនីតិវិធីណាមួយឡើយ លើកលែងតែឯកសារនេះ ត្រូវបានប្រើប្រាស់សម្រាប់ធ្វើជាភស្តុតាងប្រឆាំងនឹងជនជាប់ចោទនៃអំពើទារុណកម្ម ដោយសារមានការចង្អុលបង្ហាញក្នុងសេចក្តីថ្លែងការណ៍។[19]*

ភាគីសហព្រះរាជអាជ្ញាបានតវ៉ាថា ក្រុមមេធាវីការពារក្តី មិនបានអើពើត្រង់ឃ្លាចុងក្រោយនៃមាត្រា១៥ ដែលអនុញ្ញាតឲ្យប្រើប្រាស់នូវភស្តុតាងដែលទទួលបានតាមរយៈធ្វើទារុណកម្ម ដោយសារតែភស្តុតាងនោះ គឺជាសេចក្តីថ្លែងការណ៍មួយដែលពិតជាបានធ្វើឡើងប្រាកដមែន។ សហព្រះរាជអាជ្ញា **អាប់ឌុលឡាក់** ក៏បានចង្អុលបង្ហាញថា ឯកសារទាំងនេះ ត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដើម្បីបង្ហាញថាឯកសារទាំងនេះត្រូវបានធ្វើឡើងតាមវិធីណា ហើយអ្នកណាជាអ្នកបានឃើញឯកសារទាំងនោះ។ សហព្រះរាជអាជ្ញា បានលើកឡើងទៀតថា គោលបំណងនៃការប្រើប្រាស់ឯកសារទាំងនេះ គឺដើម្បីបង្ហាញឲ្យឃើញថាតើនរណាត្រូវបានគេសួរ នរណាជាអ្នកសួរ ហើយនរណាបានរាយការណ៍ ហើយរាយការណ៍ទៅឲ្យនរណា ។ ទោះជាយ៉ាងនេះក្តី ការបង្ហាញឯកសារ

ប្រភេទនេះ គឺមិនមែនពឹងផ្អែកទៅលើខ្លឹមសារនៃឯកសារទាំងនេះ ដើម្បីបញ្ជាក់ថាខ្លឹមសារទាំងស្រុងនៃឯកសារទាំងនេះ ជាការពិតនោះទេ (គ្រាន់តែចង់ដឹងពីបរិបទទូទៅ ចំណងពាក់ព័ន្ធដែលអាចជាប្រយោជន៍ដល់ការចោទប្រកាន់ទៅកាន់ថ្នាក់ដឹកនាំជាន់ខ្ពស់របស់ខ្មែរក្រហម)។ ជាការឆ្លើយតបទៅនឹងការដកស្រង់របស់មេធាវីការពារក្តីគឺលោក **អ៊ីនូហ្សី** ដែលបានដកស្រង់នូវសម្រង់មួយចំនួនពីប្រតិចារឹកនៃសំណុំរឿង០០១ សហព្រះរាជអាជ្ញា **អាប់ឌុលឡាក់** បានចង្អុលបង្ហាញថា ថ្វីបើអង្គជំនុំជម្រះធ្លាប់បានទទួលស្គាល់ចំពោះការប្រើប្រាស់នូវឯកសារនានាដែលបានពីការធ្វើទារុណកម្មនៅក្នុងសំណុំរឿង០០១ ក៏ពិតមែន ក៏អង្គជំនុំជម្រះធ្វើឡើងក្នុងគោលបំណងដើម្បីសួរដេញដោលលើការចោទប្រកាន់ដែលបានធ្វើក្នុងការប្រឆាំងទៅលើជនដៃដល់ ។

### *ឃ.៣. ប្រតិចារឹកនៃសំណុំរឿង ០០១*

ក្រុមមេធាវីការពារក្តី ក៏បានធ្វើការជំទាស់ផងដែរថា ប្រតិចារឹកនៃសំណុំរឿង០០១ មិនគួរត្រូវបានទទួលយកមកជាឯកសារភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះនៃសំណុំរឿង០០២ទេ។ លោក **កាណាវ៉ាស** បានធ្វើការតវ៉ាម្តងទៀតនូវគោលបំណងជំទាស់ដូចគ្នា ដែលគាត់ធ្លាប់បានធ្វើកាលពីសវនាការមុនៗដោយបានចង្អុលបង្ហាញថា នៅក្នុងសំណុំរឿង០០១ មេធាវីការពារក្តីឲ្យលោក **ឌុច** បានពឹងផ្អែកទៅលើការពិភាក្សានានាពីក្រុមមេធាវីការពារក្តីផ្សេងៗទៀត ពីព្រោះតែលោក **ឌុច** បានសារភាពទទួលស្គាល់នូវកំហុសខ្លួន។ លទ្ធផលនៃការទទួលស្គាល់ទោសទណ្ឌរបស់គាត់នេះហើយ ធ្វើឲ្យមានការតទល់ជជែកដេញដោលទៅកាន់សាក្សី មិនសូវមានលក្ខណៈស្វិតស្វាញ ឬការសួរដេញដោលនាពេលនោះ ហាក់ដូចជាមិនបានធ្វើឲ្យខ្លាំងក្លាពេញដៃពេញជើងឡើយនៅក្នុងសំណុំរឿង០០១។ ម៉្យាងវិញទៀត លោក **កាណាវ៉ាស** បានជំទាស់ចំពោះការចង់ប្រើប្រាស់ប្រតិចារឹក នៃសំណុំរឿង ០០១ និងថា អង្គជំនុំជម្រះ មិនគួរទទួលយកឯកសារប្រភេទនេះមកធ្វើជាភស្តុតាងទេ។ ជាងនេះទៅទៀត សាក្សីនៃសំណុំរឿង០០១ គួរតែត្រូវបានកោះហៅជាថ្មីម្តង ទៀតឲ្យមកឆ្លើយបំភ្លឺ និងនូវសំណួររបស់ក្រុមមេធាវីការពារក្តីនាពេលបច្ចុប្បន្ននេះ។ លោក **កាណាវ៉ាស** បានដកស្រង់នូវករណីផ្លូវច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ **អាយ.ស៊ី.ធី.វ៉ាយ** ក្នុងការគាំទ្រសេចក្តីអះអាងរបស់គាត់។

លោកស្រី **ហ្គីសសេ** ក៏បានគាំទ្រនូវសេចក្តីសម្តាងរបស់លោក **កាណាវ៉ាស** ដោយបានតវ៉ាបន្ថែមទៀតថា **អ.វ.ត.ក** បានអនុវត្តយកប្រព័ន្ធតទល់គ្នា ហេតុដូច្នេះ ប្រតិចារឹកដែលបានមកពីសវនាការនៃសំណុំរឿងដាច់ដោយឡែកពីគ្នាមុនៗ មិនគួរត្រូវបានទទួលយកជាភស្តុតាងទេ។

សហព្រះរាជអាជ្ញា **លីសាក់** បានតវ៉ាអំពីការលើកឡើងរបស់ភាគីការពារក្តីថា សក្ខីកម្មដែលបានមកពីសាក្សីនៅក្នុងសំណុំរឿង០០១ គួរត្រូវបានចាត់ទុកថាវាដូចគ្នានឹងសក្ខីកម្មរបស់សាក្សីដទៃទៀតដែរ ហើយដែលសក្ខីកម្មទាំងនេះ អាចនឹងជួយបំពេញបន្ថែមដល់សក្ខីកម្មរបស់សាក្សីថ្មីជាក់លាក់ណាម្នាក់។ លោក **លីសាក់** បានយល់ព្រមចំពោះការទាមទារពីភាគីការពារក្តីក្នុងការសួរដេញដោលមួយជុំទៀតទៅលើសាក្សីចាស់ៗទាំងនេះ និង

បានថ្លែងបន្ថែមទៀតថា លោក **ឌុច** នឹងផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះដើម្បីផ្តល់ឱកាសឲ្យភាគីទាំងអស់អាចធ្វើការប្រៀបធៀបបាននូវសក្ខីកម្មរបស់គាត់ ជាមួយនឹងសេចក្តីថ្លែងការណ៍នានាដែលគាត់បានធ្វើក្នុងសំណុំរឿង០០១។

### *ឃ.៤. ការពិនិត្យលើការជំទាស់ឡើងសាជាថ្មីលើស្តង់ដារនៃការទទួលយកឯកសារ*[20]

ការជជែកពិភាក្សាលើការទទួលយកបាននៃឯកសារ គឺជាប្រធានបទដ៏ក្តៅគគុកមួយ ដែលត្រូវបានលើកឡើងម្តងហើយម្តងទៀត ចំពោះឯកសារទាំងឡាយ ដែលត្រូវបានដាក់បង្ហាញកាលពីកិច្ចដំណើរការនីតិវិធីនៃសវនាការលើភស្តុតាង។[21]

### *ឃ.៤.ក. ការឃើញមួយក្រឡេកភ្នែកដែលគួរឲ្យជឿជាក់បាន*

លោកសហព្រះរាជអាជ្ញា **វ៉េង ហ៊ាត់** បានលើកឡើងជាថ្មីម្តងទៀតអំពីនិយមន័យនៃស្តង់ដារលើការទទួលយកភស្តុតាងដោយក្រឡេកមួយភ្នែក។ គាត់បានដកស្រង់នៃវិធានផ្ទៃក្នុង ៨៧(១) លើវិធានផ្ទៃក្នុងស្តីពីភស្តុតាងដោយលើកឡើងថា "លើកលែងតែមានបទប្បញ្ញត្តិផ្សេងក្នុងវិធានផ្ទៃក្នុងនេះ រាល់ភស្តុតាងទាំងអស់ត្រូវតែទទួលយក"។ អង្គជំនុំជម្រះ បានចេញសេចក្តីសម្រេចចំពោះឯកសារលេខ E162 ដែលបានធ្វើឡើងនៅក្នុងថ្ងៃទី៣១ ខែមករា ឆ្នាំ២០១២។ ភាគីសហព្រះរាជអាជ្ញា បានធ្វើការបកស្រាយលើវិធាននេះក្រោមខ្លឹមសារដូចតទៅ៖ ដើម្បីឲ្យអង្គជំនុំជម្រះសម្រេចពីការអាចទទួលយកបាននៃភស្តុតាង ដែលបានដាក់បង្ហាញនៅចំពោះមុខខ្លួន អង្គជំនុំជម្រះ គួរតែធ្វើតាមស្តង់ដារនៃការអាចវាយតម្លៃបាន ដោយគ្រាន់តែមើលឃើញមួយក្រឡេកភ្នែកនូវយថាភាពរបស់ឯកសារនោះថា មានភាពពាក់ព័ន្ធ និងភាពគួរទុកចិត្តបាន។ ក្នុងករណីដែលមានការខ្វះខាតនូវលក្ខខណ្ឌសំខាន់ៗខាងលើនេះ ឯកសារនោះអាចនឹងត្រូវបានចាត់ទុកថា ជាឯកសារដែលមិនអាចបង្ហាញការពិតនៃអង្គហេតុ ឬផ្នែកណាមួយនៃអង្គហេតុ។ ប្រការនេះ វានឹងត្រូវបានចាត់ទុកថាមិនអាចទទួលយកបានយោងតាមវិធានផ្ទៃក្នុង ៨៧.៣.គ ។[22] ជាមួយនេះផងដែរ ប្រសិនបើមិនមានការគូសបញ្ជាក់ណាមួយថា ឯកសារនោះជាឯកសារក្លែងក្លាយ ជាឯកសារក្លែងបន្លំទេ មានន័យថា វានឹងត្រូវបានសន្មតទុកថាជាឯកសារមានយថាភាព និងការជឿទុកចិត្តបាន។ ហេតុដូចនេះ មិនមានភាពចាំបាច់ឡើយក្នុងការបង្ហាញឯកសារដើម ឬការទាមទារឲ្យមានសាក្សីមកធ្វើការបញ្ជាក់ពីយថាភាពឯកសារ ហើយក៏រឹតតែមិនចាំបាច់ធ្វើការបង្ហាញពីខ្សែចង្វាក់នៃការរក្សាទុកឯកសារ ដើម្បីអាចឈានទៅរកការទទួលយកបានជាឯកសារជាភស្តុតាងឡើយ ។

លោក **វ៉េង ហ៊ាត់** បានលើកឡើងថា **អ.វ.ត.ក** បានអនុវត្តប្រព័ន្ធច្បាប់ស៊ីវិល ជាច្បាប់ដែលគាំទ្រនូវគោលការណ៍វាយតម្លៃភស្តុតាងដោយសេរី។ យោងតាមគោលការណ៍នេះ ស្តង់ដារនៃការទទួលយកបាននៃឯកសារ គឺមានកម្រិតទាបបំផុត ដែលប្រការនេះអនុញ្ញាតឲ្យចៅក្រមដែលមានវិជ្ជាជីវៈខ្ពស់អាចធ្វើការវាយតម្លៃ និងផ្តល់នូវទម្ងន់នៃភស្តុតាង ក្នុងដំណាក់កាលនីតិវិធីសវនាការនាពេលខាងមុខជាបន្តបន្ទាប់ទៀត។ យោងតាមភាគីសហ

ព្រះរាជអាជ្ញាបានឲ្យដឹងថា តុលាការព្រហ្មទណ្ឌពិសេសនៃប្រទេស **សៀរ៉ាឡេអូន** បានប្រើប្រាស់ប្រព័ន្ធយុត្តាធិការបែបនេះ និងថែមទាំងបានអនុញ្ញាតឲ្យចៅក្រមពឹងផ្អែកលើភស្តុតាងដែលបានពីពាក្យចចាមអារ៉ាមទៀតផង (ភស្តុតាងចចាមអារ៉ាម)។ សហព្រះរាជអាជ្ញារូបនេះ បានបញ្ជាក់បន្ថែមទៀតថា **អ.វ.ត.ក** គឺខុសប្លែកពីប្រព័ន្ធច្បាប់របស់តុលាការ **អាយ.ស៊ី.ធី.វ៉ាយ** ដូច្នេះ ការសម្អាងរបស់មេធាវី **កាណាវ៉ាស** លើករណីផ្លូវច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ **អាយ.ស៊ី.ធី.វ៉ាយ** គឺមិនពាក់ព័ន្ធទៅនឹងបញ្ហានេះទេ ។

### *ឃ.៤.ខ. ឯកសារដើម*

ក្រុមមេធាវីការពារក្តីឲ្យលោក **នួន ជា** បានបន្តទាមទារសុំឲ្យមានការបង្ហាញឯកសារដើម និងមិនមែនជាឯកសារដែលបានពីការប្រើប្រាស់បច្ចេកវិទ្យាថតចម្លងផ្សេងៗ ដូចជា ស្កេន ឬម៉ាស៊ីនថតចម្លងឡើយ។ លោក **សុន អរុណ** បានបដិសេធទាំងស្រុងនូវឯកសារនៅក្នុងឧបសម្ព័ន្ធលេខរៀងទី៧ ដែលមិនមានឯកសារច្បាប់ដើមឡើយ និងមានតែឯកសារថតចម្លង ហើយដែលគុណភាពទៀតសោត ក៏ពិបាកនឹងទទួលយកបាន ដោយសារមើលមិនច្បាស់។ លោកមេធាវី បានស្នើសុំមើលឯកសារដើម ដើម្បីផ្ទៀងផ្ទាត់អំពីយថាភាពនៃឯកសារថតចម្លងទាំងនោះ។

### *ឃ.៤.គ. ដំណើរការថែរក្សាភស្តុតាង*

ក្រុមមេធាវីការពារឲ្យលោក **នួន ជា** ហើយនិងមេធាវីការពារក្តីលោក **ខៀវ សំផន** បានថ្លែងពីការជំទាស់ជាថ្មីម្តងទៀតទាក់ទងនឹងឯកសារទាំងឡាយ ដែលពួកគាត់បានចាត់ទុកថាខ្វះនូវការបង្ហាញឲ្យឃើញពីដំណើរការថែរក្សាភស្តុតាង បូករួមទាំងភាពមិនច្បាស់លាស់នូវព័ត៌មានមួយចំនួនផងដែរ។ លោក **អ៊ីនូហ្សុី** បានតវ៉ាថា ឯកសារទាំងនោះ មិនគួរត្រូវបានទទួលស្គាល់នោះទេ ប្រសិនបើអ្នកនិពន្ធ និងអ្នកថែរក្សា មិនបានមកផ្តល់សក្ខីកម្មដើម្បីស្រាយបំភ្លឺថាតើឯកសារទាំងនោះធ្វើឡើងដោយរបៀបម៉េច ហើយនរណាជាអ្នកគ្រប់គ្រង នរណាជាអ្នករកឃើញ និងថាតើឯកសារទាំងនោះត្រូវបានពន្យល់ និងណែនាំថាជាឯកសារភស្តុតាងដោយរបៀបណា។ លោកស្រី **ហ្គីសសេ** បានចោទជាសំណួរថាតើឯកសារទាំងនោះធ្វើឡើងដោយរបៀបណា ព្រាងដោយរបៀបណា បានរក្សាទុកដោយរបៀបណា ហើយថាតើបានអភិរក្សរបៀបណាខ្លះ បូករួមទាំងឯកសារដែលបានមកពី **ឌី.ស៊ី.ខេម** ហើយក៏ដូចជា ឯកសារក្នុងឧបសម្ព័ន្ធលេខរៀងទី៦ ទី៧ និងឧបសម្ព័នលេខរៀងទី១៧ ពីព្រោះតែមិនទាន់មានការចង្អុលបង្ហាញនៅឡើយ ថាតើឯកសារទាំងនេះត្រូវបានធ្វើឡើងដោយវិធីណា។

លោកសហព្រះរាជអាជ្ញា **វ៉េង ហ៊ត់** បានធ្វើការឆ្លើយតបថា មិនមានភាពចាំបាច់អ្វីក្នុងការបង្កើតឲ្យមានខ្សែចង្វាក់នៃការកាន់កាប់ថែរក្សាឯកសារទាំងនោះទេ ដោយសារវាបានឆ្លុះបង្ហាញអំពីការជាប់ពាក់ព័ន្ធជាមួយនឹងភស្តុតាងនានាដែលបានមកពីឯកសារដទៃទៀត ឬបានមកពីសាក្សី គឺមានលក្ខណៈសម្បត្តិពេញលេញក្នុងការបង្ហាញថា ឯកសារទាំងនេះ មានភាពគួរឲ្យជឿទុកចិត្តបាន។ សហព្រះរាជអាជ្ញា បានអះអាងទៀតថា សាក្សីពីររូប

គឺលោក **ឆាំង យុ** និងលោក **វ៉ាន់ចាន់ ពៅដារា** ដែលជាបុគ្គលិកចជាន់ខ្ពស់របស់ **ឌី.ស៊ី.ខេម** បានផ្តល់សក្ខីកម្មគ្រប់គ្រាន់ហើយស្តីអំពីវិធីសាស្ត្រនៃការប្រមូល និងទទួលយកឯកសារ។ សហភាតាអន្តរជាតិរបស់គាត់ គឺលោក **អាប់ឌុលឡាក់** បានបន្ថែមថា ការិយាល័យសហព្រះរាជអាជ្ញា បានធ្វើការទាក់ទងជាមួយនឹងបណ្ណសារដ្ឋានជាតិដើម្បីស្នើសុំថតចម្លងចេញមកពីឯកសារដើមមួយចំនួនដែលមាននៅទីនោះ។ ដូចនេះ សបញ្ជាក់ឲ្យឃើញថា ភាគីសហព្រះរាជអាជ្ញាមិនមែនពឹងផ្អែកទាំងស្រុង ឬជឿលើ **ឌី.ស៊ី.ខេម** តែប៉ុណ្ណោះទេ។

### *ឃ.៤.ឃ. ឯកសារដែលមិនទាន់មានការបកប្រែ*

ក្រុមមេធាវីការពារឲ្យលោក **នួន ជា** និងលោក **អៀង សារី** បានជំទាស់លើឯកសារមួយចំនួន ដែលបានលើកឡើងដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រោមហេតុផលថា ឯកសារមួយចំនួនមិនទាន់បានធ្វើការបកប្រែទៅជាភាសាប្រើប្រាស់ជាផ្លូវការនៅ **អ.វ.ត.ក** នៅឡើយ។ មេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺលោកស្រី**អេលី ហ្សាបេត ស៊ីម៉ុនណូហ្វត** បានពន្យល់ប្រាប់តុលាការថា ក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់សំណើសុំឲ្យធ្វើការបកប្រែនូវឯកសារទាំងនេះហើយ ក៏ប៉ុន្តែពួកគាត់មិនទាន់បានទទួលការឆ្លើយតបពីអង្គភាពបកប្រែនៅឡើយទេ។ ចំណុចនេះ នាំឲ្យមេធាវីការពារក្តីលោក **អ៊ីនូហ្ស៊ី** និងលោក **កាណាវ៉ាស** បានប្រកាសភ្លាមៗថា ខណៈពេលដែលពួកគាត់មិនមានបំណងធ្វើការជំទាស់ទៅលើខ្លឹមសារក្នុងឯកសារដែលបង្ហាញដោយភាគីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណាក់កាលនេះទេ ក៏ប៉ុន្តែពួកគាត់នឹងរក្សាសិទ្ធិក្នុងការជំទាស់នៅពេលដែលឯកសារទាំងនោះត្រូវបានបកប្រែរួចស្រេចបាច់ហើយ ។

### *ឃ.៤.ង. ការចោទប្រកាន់នូវភាពលម្អៀងពីមុខងារការិយាល័យសហចៅក្រមស៊ើបអង្កេត*

ក្រុមមេធាវីការពារក្តី បានធ្វើការចោទប្រកាន់ទៅកាន់ការិយាល័យសហចៅក្រមស៊ើបអង្កេតថា ជាស្ថាប័នលម្អៀង ដូច្នេះ រាល់ឯកសារដែលបានមកពីការិយាល័យសហចៅក្រមស៊ើបអង្កេតទាំងអស់ មិនត្រូវទទួលយកជាភស្តុតាងដោយស្វ័យប្រវត្តិនោះទេ។ ការលើកឡើងនេះ បានធ្វើឲ្យសហព្រះរាជអាជ្ញាអន្តរជាតិលោក **វ៉ាំងសង់ វ៉ាយឌ៍ ដេស្មាឯល** *(Mr. Vincent De Wilde d'ESTMAEL)* បានឆ្លើយតបដោយតវ៉ាថា យោងតាមនីតិវិធីជាស្តង់ដារមួយ គឺថាបុគ្គលិកនៃការិយាល័យសហចៅក្រមស៊ើបអង្កេតសុទ្ធតែបានធ្វើសច្ចាប្រណិធាន (ស្បថ) មុននឹងបានបំពេញការងាររបស់ពួកគេនៅក្នុងការស្វែងរកនូវភស្តុតាងទាំងដាក់បន្ទុក និងដោះបន្ទុក។ លោក ក៏បានចង្អុលបង្ហាញទៀតថា ក្រុមមេធាវីការពារក្តី មិនបានបង្ហាញភស្តុតាងណាមួយក្នុងការគាំទ្រដល់ការទាមទារដែលថាការិយាល័យសហចៅក្រមស៊ើបអង្កេត ថាជាអង្គភាពមានលម្អៀង ។

### *ឃ.៤.ច.	ពេលវេលា “សមស្រប” ក្នុងការទទួលយកឯកសារនានា*

លោក **កាណាវ៉ាស** ជាថ្មីម្តងទៀត បានលើកឡើងនូវបញ្ហាមួយ ស្តីពីថាតើអ្វីដែលហៅថាជា “ពេលវេលាសមរម្យ” ក្នុងការដាក់បង្ហាញឯកសារនៅចំពោះមុខអង្គជំនុំជម្រះ។ ជាមួយនឹងការថ្លែងជាថ្មីម្តងទៀត នូវអ្វីដែលគាត់ធ្លាប់បានលើកឡើងកាលពីវគ្គសវនាការមុនៗ មេធាវីរូបនេះបានតវ៉ាថា ភាគីសហព្រះរាជអាជ្ញាគប្បីរង់ចាំសាក្សីដែលមានការជាប់ពាក់ព័ន្ធឲ្យមកធ្វើការបង្ហាញខ្លួនជាមុនសិន មុនពេលធ្វើការណែនាំឲ្យមានការទទួលយកឯកសារទាំងនោះ ប្រសើរជាជាងដាក់ជូននៅចំពោះមុខអង្គជំនុំជម្រះនូវឯកសារទាំងដុល និងដ៏ច្រើនលើសលប់ដូច្នេះ ។

## *ជំពូកទី ៣៖*	**ការគ្រប់គ្រងសវនាការ**

មានការព្រួយបារម្ភស្តីពីបញ្ហានៃការគ្រប់គ្រងសវនាការរបស់អង្គជំនុំជម្រះនៅសប្តាហ៍ក្រោយ ទាក់ទងនឹងករណីរបស់លោក **នួន ជា** ដែលស្នើសុំមានវត្តមាននៅក្នុងបន្ទប់សវនាការ ក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់លោក **ឌុច**។ ទោះបីជាមានបញ្ហាជាច្រើនត្រូវបានលើកឡើងយកមកពិភាក្សានៅសប្តាហ៍នេះក្តី ក៏អង្គជំនុំជម្រះ និងភាគីដទៃទៀត នៅតែរក្សាបាននូវអាកប្បកិរិយាសមរម្យ នាំឲ្យសវនាការអាចចៀសវាងបាននូវការកើតឡើងបញ្ហាកំប៉ិកកំប៉ុកនានា។

### ក.	វត្តមាន

ជនជាប់ចោទទាំងអស់ បានមានវត្តក្នុងបន្ទប់សវនាការ នៅវគ្គទីមួយជារៀងរាល់ពេលព្រឹកនៅសប្តាហ៍នេះ។ បន្ទាប់ពីសវនាការវគ្គពេលព្រឹកចប់ លោក **នួន ជា** បានស្នើសុំទៅចូលរួមសវនាការនៅបន្ទប់សោតទស្សន៍ពេញមួយរសៀល។ លោក **ខៀវ សំផន** បានមានវត្តមាននៅក្នុងបន្ទប់សវនាការគ្រប់វគ្គនៃកិច្ចដំណើរការនីតិវិធីទាំងអស់។ នៅថ្ងៃច័ន្ទ លោក **អៀង សារី** មានវត្តមានក្នុងបន្ទប់សវនាការទាំងពីរវគ្គ គឺវគ្គទីមួយ និងវគ្គទីពីរ (ពេញមួយព្រឹក) ហើយក្រោយមកគាត់ក៏បានចូលរួមសវនាការពីចម្ងាយនៅបន្ទប់សោតទស្សន៍វិញ (ពេលរសៀល)។

លោកស្រីចៅក្រម **ខាតរ៉ាយថ៍** បានត្រឡប់មកតុលាការវិញ បន្ទាប់ពីលោកស្រីបានអវត្តមាន កាលពីសប្តាហ៍មុន ដោយសារតែបញ្ហាសុខភាព។ នៅថ្ងៃច័ន្ទរសៀលនេះ អង្គជំនុំជម្រះ បានប្រកាសទទួលស្គាល់មេធាវីអន្តរជាតិការពារក្តីឲ្យលោក **ខៀវ សំផន** មួយរូប គឺលោកស្រី **អង់តា ហ្គីសសេ** ដែលកន្លងមកត្រូវបានអង្គជំនុំជម្រះអនុញ្ញាតឲ្យមានវត្តមាននៅក្នុងបន្ទប់សវនាការ ប៉ុន្តែមិនអនុញ្ញាតឲ្យនិយាយ ឬបញ្ចេញមតិយោបល់អ្វីឡើយនៅក្នុងសវនាការកន្លងទៅកាលពីសប្តាហ៍មុនៗ។ លោកស្រី **ហ្គីសសេ** គឺជាសមាជិកមួយរូបនៃគណៈមេធាវីក្រុងប៉ារីស ប្រទេសបារាំង ហើយក៏ជាមេធាវីម្នាក់ ដែលធ្លាប់មានបទពិសោធន៍ការងារនៅតុលាការអន្តរជាតិ **អាយ.ស៊ី.ធី.អ័រ** ផងដែរ ។

**ការចូលរួមពីសាធារណជន៖** នៅថ្ងៃច័ន្ទនេះ យ៉ាងហោចណាស់ មានសិស្សានុសិស្ស ប្រមាណជា២៥០នាក់ មកពីវិទ្យាល័យព្រះយុគន្ធរ រាជធានីភ្នំពេញ បានចូលរួមសវនាការពេញមួយថ្ងៃ។ នៅថ្ងៃអង្គារ មានសិស្សានុសិស្សប្រមាណជា ៣០០នាក់ មកពីវិទ្យាល័យមួយនៃខេត្តបាត់ដំបង បានចូលរួមសវនាការនៅពេលព្រឹក ក៏ប៉ុន្តែបានចាកចេញបន្ទាប់ពីសម្រាកបរិភោគអាហារថ្ងៃត្រង់ ហើយមានសិស្សានុសិស្សមកពីវិទ្យាល័យច្បារអំពៅនៃទីក្រុងភ្នំពេញ ប្រមាណជា២៥០នាក់ បានមកចូលរួមសវនាការជំនួសនៅពេលរសៀល។ នៅថ្ងៃពុធ មានសិស្ស ៣០០នាក់ មកពីវិទ្យាល័យឬស្សីកែវ រាជធានីភ្នំពេញ បានមកចូលរួមសវនាការ។ ដោយឡែក នៅថ្ងៃចុងក្រោយនៃសវនាការសប្តាហ៍នេះ គឺនៅថ្ងៃព្រហស្បតិ៍ មានសិស្សានុសិស្សប្រមាណជា ៣០០នាក់ មកពីវិទ្យាល័យត្រាំកក់នៃខេត្តតាកែវ បានចូលរួមតាមដានសវនាការ។

## ខ. ឥរិយាបថក្នុងបន្ទប់សវនាការ

កាលពីថ្ងៃច័ន្ទលោក **កាណាវ៉ាស** បានចោទប្រកាន់ភាគីសហព្រះរាជអាជ្ញាថា បាននឹងកំពុងតែឆ្លៀតឱកាសបន្លំដាក់បញ្ចូល[23] ឯកសារមួយចំនួន ដើម្បីប្រើប្រាស់ជាភស្តុតាងនៅក្នុងកិច្ចដំណើរការនីតិវិធី ដោយការរៀបចំឈ្មោះបញ្ជីឯកសារខុសពីសំណុំឯកសារពិត និងបានដាក់សញ្ញាណសម្គាល់ឯកសារខុសពីប្រភេទត្រឹមត្រូវនៃឯកសារទាំងនោះ។ បន្ថែមពីនេះលោក **កាណាវ៉ាស** បានថ្លែងទៀតថា ការធ្វើដូចនេះ នាំឲ្យយើងមានចម្ងល់ពីជំនាញវិជ្ជាជីវៈរបស់បុគ្គលិកនៃការិយាល័យសហព្រះរាជអាជ្ញា។ ការលើកឡើងបែបនេះ ធ្វើឲ្យមានការជំទាស់តវ៉ាពេញមួយសប្តាហ៍ពីសំណាក់សហព្រះរាជអាជ្ញាបីរូប ដែលបានធ្វើការថ្លែងតបថា ការលើកឡើងរបស់លោក **កាណាវ៉ាស** គឺមិនត្រឹមត្រូវទេ ហើយការចោទប្រកាន់ដូច្នេះ ក៏មិនមានភាពសមរម្យដែរ។ បន្ទាប់ពីនេះ លោក **កាណាវ៉ាស** ក៏បានទទួលស្គាល់កំហុស និងបានសុំទោសចំពោះសហព្រះរាជអាជ្ញាចំពោះការប្រើសម្តីធ្ងន់បន្តិចរបស់គាត់។

បន្ថែមទៅលើព្រឹត្តិការណ៍នៃការចោទប្រកាន់នៅក្នុងបន្ទប់សវនាការ លោក **កាណាវ៉ាស** ក៏បានថ្លែងផងដែរថា មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនសូវបានធ្វើអ្វីជាដុំកំភួន ក្រៅពីធ្វើការសម្តែងមតិយោបល់យល់ស្របនូវជំហាររបស់សហព្រះរាជអាជ្ញាតែប៉ុណ្ណោះ។ អ្នកស្រី **ស៊ីម៉ុនណូហ្សត** បានបកស្រាយថា ទង្វើរបស់ក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺធ្វើឡើងដើម្បីបញ្ជាក់ពីតួនាទីក្នុងនាមខ្លួនជាមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណើរការនីតិវិធីតុលាការទៅវិញទេ។ ផ្សារភ្ជាប់ទៅបញ្ហានេះផងដែរ លោកមេធាវី **ផេស្តមិន** បានសុំការអធ្យាស្រ័យចំពោះការក្រោកឈរលឿនពេក នៅពេលដែលចង់ឡើងសម្តែងយោបល់ដោយគាត់បាននិយាយថា គាត់ភ្លេចខ្លួនថានៅមានវត្តមានរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅពេលនោះ ដែលត្រូវធ្វើការលើកឡើងមតិយោបល់អ្វីមួយបន្ទាប់ពីភាគីសហព្រះរាជអាជ្ញាបានធ្វើការថ្លែងចប់ ។

**ការប្រើប្រាស់ពាក្យ ““*មីនីត្រាល*” Mini-Trial (សវនាការខ្នាតតូច)”៖** នៅថ្ងៃអង្គារ បន្ទាប់ពីលោកស្រី **ហ្វីសសេ** បានប្រើពាក្យមួយគឺ “*មីនីត្រាល*” ចំនួនបី ឬបួនដង ធ្វើឲ្យសហព្រះរាជអាជ្ញា **អាប់ឌុលឡាក់** បានជំរុញ

ឲ្យភាគីទាំងអស់គួរប្រើពាក្យជាផ្លូវការមួយថា  នេះគឺជាសវនាការនៅដំណាក់កាលដំបូងនៃសំណុំរឿង០០២/០១ ក្រោមការសម្អាងថាការប្រើពាក្យ មីនីត្រាល គឺជាការបំពានដល់ជនរងគ្រោះ។ នៅថ្ងៃព្រហស្បតិ៍ លោក **អ៊ីនូហ្ស៊ី** បានបដិសេធមិនយល់ព្រមនឹងការស្នើរបស់សហព្រះរាជអាជ្ញា និងបានថ្លែងថា គ្រប់ភាគីទាំងអស់ ក៏ដូចជាប្រព័ន្ធផ្សព្វផ្សាយព័ត៌មានមួយចំនួន ក៏បានប្រើពាក្យនេះដូចគ្នាជាប្រចាំទៅហើយ។ ពួកគេទាំងអស់បានប្រើប្រាស់ពាក្យនេះ ដោយមិនមានន័យអ្វីទៅបំពារបំពានភាគីណាឡើយ ពីព្រោះតែការនិយាយថា សំណុំរឿង០០២ ដំណាក់កាលទី១ វាមិនមែនជាពាក្យស្រួលយល់នោះទេ។ បន្ថែមពីនេះទៀត លោកបានពន្យល់ថា តាមពិតទៅ នេះគឺជាសវនាការនៃដំណាក់កាលតូចៗ បើធ្វើការប្រៀបធៀបទៅនឹងសំណុំរឿងដើមទាំងមូលនោះ គឺសំណុំរឿង០០២។ យោងតាមហេតុផលនេះ យើងសង្កេតឃើញថា ក្រុមមេធាវីការពារក្ដីនៅតែបន្តប្រើប្រាស់ពាក្យ សវនាការនៅដំណាក់កាលដំបូងថាជា “មីនីត្រាល” (សវនាការខ្នាតតូច) ។

នៅរសៀលថ្ងៃព្រហស្បតិ៍នេះ អង្គជំនុំជម្រះ បានធ្វើការណែនាំឲ្យភាគីមិនឲ្យប្រើប្រាស់ពាក្យ *មីនីត្រាល* (សវនាការខ្នាតតូច) ដោយបានថ្លែងថា វាជាពាក្យមិនសមរម្យ ហើយថាការប្រើប្រាស់ពាក្យនេះ (សវនាការខ្នាតតូច) មិនបានឆ្លើយតបនឹងរយៈកាលជាក់ស្ដែង ភាពធំដុំ និងភាពសំខាន់នៃដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ វគ្គទី១ ឡើយ ។

## ឃ. តារាងពេលវេលា

| កាលបរិច្ឆេទ | ចាប់ផ្ដើម | សម្រាកពេលព្រឹក | អាហារថ្ងៃត្រង់ | សម្រាកពេលរសៀល | បិទសវនាការ | ចំនួនម៉ោងសរុប |
|---|---|---|---|---|---|---|
| ថ្ងៃច័ន្ទ ១២/០៣/១២ | ៩:០៩ | ១០:៣២-១០:៥៧ | ១២:០២-១៣:៣១ | ១៤:៣៦-១៥:០៣ | ១៥:៥២ | ៤ម៉ោង និង ២២នាទី |
| ថ្ងៃអង្គារ ១៣/០៣/១២ | ៩:០៥ | ១០:១២-១០:៣៣ | ១២:០៤-១៣:៣២ | ១៤:២៨-១៤:៥៣ | ១៦:១៤ | ៤ម៉ោង និង ៥៥នាទី |
| ថ្ងៃពុធ ១៤/០៣/១២ | ៩:០២ | ១០:២៦-១០:៥០ | ១២:០១-១៣:៣០ | ១៤:៣១-១៤:៥៤ | ១៥:៥៦ | ២ម៉ោង និង ៣៨នាទី |
| ថ្ងៃព្រហស្បតិ៍ ១៥/០៣/១២ | ៩:០១ | ១០:២៩-១០:៤៩ | ១២:១៨-១៣:៤១ | ១៤:២០-១៤:៤៨ | ១៦:១៤ | ៥ម៉ោង និង ២នាទី |
| ***ចំនួនម៉ោងជាមធ្យមក្នុងសវនាការមួយវគ្គ៖*** | | | | *៤ម៉ោង និង៤៤នាទី* | | |
| ***ចំនួនម៉ោងសរុបក្នុងសប្ដាហ៍នេះ៖*** | | | | *១៨ម៉ោង និង៥៧នាទី* | | |
| ***ចំនួនសរុបនៃម៉ោង ថ្ងៃ និងសប្ដាហ៍៖*** | | | | *១៥៦ម៉ោង និង២០នាទី* | | |
| ***រយៈពេលសវនាការចំនួន ៣៦ថ្ងៃ និងអំឡុងពេល ១០សប្ដាហ៍*** | | | | | | |

**Unless specified otherwise,**

- the documents cited in this report pertain to *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* before the ECCC;
- the quotes are based on the personal notes of the trial monitors during the proceedings;
- the figures in the *Public Attendance* section of the report are only approximations; and
- photos are courtesy of the ECCC.

**Glossary of Terms**

| | |
|---|---|
| Case 001 | *The Case of Kaing Guek Eav alias "Duch"*(Case No. 001/18-07-2007-ECCC) |
| Case 002 | *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* (Case No. 002/19-09-2007-ECCC) |
| CPC | Code of Criminal Procedure of the Kingdom of Cambodia (2007) |
| CPK | Communist Party of Kampuchea |
| CPLCL | Civil Party Lead Co-Lawyer |
| DK | Democratic Kampuchea |
| ECCC | Extraordinary Chambers in the Courts of Cambodia (also referred to as the Khmer Rouge Tribunal or "KRT") |
| ECCC Law | Law on the Establishment of the ECCC, as amended (2004) |
| ERN | Evidence Reference Number (the page number of each piece of documentary evidence in the Case File) |
| FUNK | National United Front of Kampuchea |

EAST-WEST CENTER    AIJI TRIAL MONITORING    WAR CRIMES STUDIES CENTER UNIVERSITY OF CALIFORNIA, BERKELEY

---

* This issue of KRT Trial Monitor was authored by Mary Kristerie A. Baleva, Samuel Gilg, Samantha Lee, Sovanna Sek, Penelope Van Tuyl and Alvin Yap as part of AIJI's KRT Trial Monitoring and Community Outreach Program. KRT Trial Monitor reports on Case 002 are available at <www.krtmonitor.org>, <http://forum.eastwestcenter.org/Khmer-Rouge-Trials/> and <http://socrates.berkeley.edu/~warcrime/>. AIJI is a collaborative project between the East-West Center, in Honolulu, and the University of California, Berkeley War

Crimes Studies Center. Since 2003, the two Centers have been collaborating on projects relating to the establishment of justice initiatives and capacity-building programs in the human rights sector in South-East Asia. The Program is funded by the Open Society Foundation, the Foreign Commonwealth Office of the British Embassy in Phnom Penh, and the Embassy of Switzerland in Bangkok.

1 Trial Chamber. "Update Memorandum for next document hearing (12-19 March 2012)" (2 March 2012). E172/5. [hereinafter, Schedule.] Par. 2. 1.

2 See http://www.yale.edu/history/faculty/kiernan.html

3 Duch was the Secretary of S-21, a security center in Democratic Kampuchea were at least 12,000 were imprisoned, tortured and executed. His was the first case prosecuted at the ECCC. He was found guilty of war crimes, and crimes against humanity, and was sentenced to life imprisonment. See Case 001. Supreme Court Chamber. "Appeal Judgment" (3 February 2012). F28. 320.

4 Trial Chamber. Transcript of Trial Proceedings (15 March 2012). E1/49. 1. Lines 1-3. 47.

5 A ruling on this issue could have many implications for future proceedings and the Chamber's perceived ability to administer justice. First, the Chamber's ruling could determine its policy on the need for the Accused to be physically present in court, weighed against the need to maintain efficiency of the proceedins. This may be depedent on the Chamber's interpretation of the balance of competing rights of the Accused under Article 35 (c) and Article 35 (D) of the ECCC Law[5]. Article 35 (c) demands that the trial be conducted without undue delay while Article 35 (d) requires that the Accused be present in court to answer the charges made against him. Second, as the Accused get older and perhaps face more medical problems, this could be a recurring issue before the Chamber, calling for a clear and fair policy and position from the Chamber to ensure consistency. Third, a ruling could also indicate the degree of the Chamber's reliance on medical certifications as opposed to an Accused' interpretation of his or her capabilities when deciding if the Accused can indeed be physically and mentally present in court. Forth, a ruling could clarify the Chamber's position regarding the difference, if any, between being present in person versus being connected via video link. Finally, the Chamber's ruling could decide if it considers a waiver from the Accused necessary for the Chamber to continue proceedings without the Accused being physically present in court.

6 Trial Chamber. "Memorandum: Hearing of TCE-38 and TCE-44" (6 February 2012). E166.

7 SCHEDULE. Par. 6.; Ieng Sary Defense. "Ieng Sary's response to the Co-Prosecutor's notice to the Trial Chamber and Parties regarding testimony of TCE-38 and TCE-44" (9 March 2012). E166/1/1.

8 *Prosecutor v. Tadic*. IT-94-I-T. "Decision on the Defence Motion to Summon and Protect Defence Witnesses, and on the Giving of Evidence by Video-Link" (25 June 1996). Par. 18. *Prosecutor v. Stanisic & Simatovic.* IT-03-69-T. "Decision on Prosecution Motion to Hear Witnesses by Video-Conference Link" (24 February 2010). Par. 8. 11. *Prosecutor v. Karadzic.* IT-95-5/18-T. "Decision on Prosecution's Motion to Subpoena Berko Zecevic" (20 January 2011). Par. 19

9 *Zigiranyirazo V. Prosecutor*. ICTR-2001-73-AR73. "Decision on Interlocutory Appeal" (30 October 2006); *Prosecutor v. bagosora et al.* ICTR-98-41-T. "Decision on prosecution request for testimony of witness BT via video-link" (8 October 2004). Par. 15; *Prosecutor v. Nzabonimana.* ICTR-98-44d-T. "Decision on Defence Urgent Motion to Hear Testimony of Expert Witness Dr. Susan Thomson via Video-Link" (9 March 2011). Par. 16; *Ndindiliyimana et al.* ICTR-00-56-T. "Decision on Bizimungun's Request for witness DE 4-12 to testify via Videolink" (2 November 2007); *Prosecutor v. Bagosora et al.* ICTR-9841-T. "Decision on Prosecution Request for Testimony of Witness BT via Video-Link" (8 October 2004). Par. 11.

10 Expert Justice Richard J. Goldstone testified from the United States in Case 001; Expert Stephane Hessel testified from France in Case 001; witness Long Norin testified from Banteay Meanchey Province in Case 002.

11 Trial Chamber, Transcript of Trial Proceedings (15 March 2012), E1/49.1.line 14. 107.

12 SCHEDULE. Par. 2, 1.

13 ECCC Law. Article 35.

14 ECCC. *Internal Rules (Rev. 8)" (3 August 2011). [hereafter, Internal Rules.] Rule 89 ter. "Severance: When the interest of justice so require, the Trial Chamber may at any stage order the separation of proceedings in relation to one or several accused and concerning part or the entirety of the charges contained in a Indictment. The case as separated shall be tried and adjudicated in such order as the Trial Chamber deem appropriate."

15 Internal Rules. Rule 87 (3).

16 Trial Chamber. Transcript of Trial Proceedings (12 march 2012), E1/46. 1. Line 3. 64.

17 UN Convention Against Torture and Other Cruel, Inhuman or Degrading Treatment or Punishment (4 February 1985). [hereinafterTORTURE CONVENTION]. Article 15.

18 Trial Footage. 12 March 2012. Part 3, 29:05-30:10.

19 Torture Convention. Article 15.

20 See AIJI Case 002 KRT Trial Monitor Issue No. 9. Hearing on Evidence Week 4 (16-20 January 2012)

21 See Scheduling Order E-159 and E170 respectively. Trial Chamber. "Memorandum: Scheduling of oral hearing on documents (16-19 February 2012)" (9 February 2012). E170.

[22] Internal Rules. Rule 87(3).
[23] Trial Chamber. Transcript of Trial Proceedings (12 March 2012). E1/46. 1. Line 14. 95.